# ធនាគារជាតិនៃកម្ពុជា



# របាយការណ៍ប្រចាំឆ្នាំ

# ២០០៦

## នាយកដ្ឋានត្រួតពិនិត្យ

ទំព័រទទេ

# អារម្ភកថា



ឆ្នាំ ២០០៦ ជាឆ្នាំមួយដ៏មានសារៈសំខាន់សំរាប់ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ។ ការប្រកាសប្រសិទ្ធនាមជាផ្លូវការ ដោយសម្តេច **ហ៊ុន សែន** យកឆ្នាំ ២០០៦ ជាឆ្នាំនៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងត្រូវបានកត់សំគាល់ថាជាឆ្នាំបង្គោល សំរាប់វិស័យមីក្រូហិរញ្ញវត្ថុ និងបានបង្ហាញពីកិច្ចគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះធនាគារជាតិនៃកម្ពុជា ក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុជនបទ និងក្នុងការជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។ សិក្ខាសាលាថ្នាក់តំបន់ចំនួនបីត្រូវបានរៀបចំឡើង ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន អ្នកប្រតិបត្តិផ្នែកមីក្រូហិរញ្ញវត្ថុ និង អតិថិជនរបស់មីក្រូហិរញ្ញវត្ថុ ដើម្បីផ្សព្វផ្សាយអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី និងពីអត្ថប្រយោជន៍ពីដំណើរការឆ្ពោះទៅរកសេវាហិរញ្ញវត្ថុផ្លូវការមួយ ។ កិច្ចប្រឹងប្រែងកាលពីឆ្នាំមុនរហូតមកដល់ឆ្នាំនេះ លទ្ធផលបានបង្ហាញឱ្យឃើញពីការកើនឡើងនៃមីក្រូឥណទានចំនួន ៩០% នៅឆ្នាំ ២០០៦ បើប្រៀបធៀបទៅនឹងឆ្នាំកន្លងទៅ ។

ស្របជាមួយនឹងការលើកកំពស់អោយមានការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានប្រកាន់យកកិច្ចប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីស្តារឡើងវិញនូវជំនឿទុកចិត្តនិងកសាងវិស័យហិរញ្ញវត្ថុមួយរឹងមាំដែលអាចប្រតិបត្តិប្រកបដោយប្រសិទ្ធភាពនៅក្នុងបរិដ្ឋានមួយដែលមានការផ្លាស់ប្តូរឆាប់រហ័ស ។

ឧបករណ៍ត្រួតពិនិត្យលើឯកសារត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការដាក់អោយអនុវត្ត ប្រព័ន្ធ COBRA ដែលជាឧបករណ៍ត្រួតពិនិត្យដោយប្រព័ន្ធកុំព្យូទ័រ ។ ការត្រួតពិនិត្យដល់ទីកន្លែងត្រូវបានពង្រឹង និង ចំនួនធនាគារដែលត្រូវត្រួតពិនិត្យប្រចាំឆ្នាំត្រូវបានបង្កើន ។ ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យរបស់យើងកាន់តែត្រូវបានពង្រឹងបន្តដោយមានការគាំទ្រពីស្ថាប័នអន្តរជាតិ ។ បទប្បញ្ញត្តិប្រុងប្រយ័ត្នត្រូវបានកែសំរួលឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម ដើម្បីសំរបសំរួលទៅតាមការផ្លាស់ប្តូរនៅក្នុងឧស្សាហកម្មធនាគារ ។ ក្នុងឆ្នាំ ២០០៦ មានប្រកាសចំនួន ៧ ត្រូវបានចេញផ្សព្វផ្សាយ និងដាក់អោយអនុវត្ត ។

ជាលទ្ធផល វិស័យហិរញ្ញវត្ថុនៅកម្ពុជាបានបង្កើនតួនាទីអន្តរការីយកម្មយ៉ាងខ្លាំងក្លានៅក្នុងការគៀងគរ និង បែងចែកប្រាក់សន្សំក្នុងស្រុកសំរាប់ការវិនិយោគ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងយ៉ាងខ្លាំងនៅក្នុងសំពៀតឥណទាន ចំនួន ៤២% និងប្រាក់បញ្ញើអតិថិជនចំនួន ៤៥% ហើយជាមួយគ្នានេះអត្រាឥណទានមិនដំណើរការ

មានកំរិតសំរម្យចំនួន ៩,៨% ។ ប្រព័ន្ធចែករំលែកព័ត៌មានត្រូវបានដាក់អោយប្រើប្រាស់នៅខែសីហា ឆ្នាំ ២០០៦។ នៅពេលដែលអនុវត្តបានពេញលេញត្រូវបានរំពឹងទុកថា នឹងបង្កើនការផ្តល់កម្ចី និងធ្វើអោយអត្រាឥណទានមិនដំណើរការមានភាពប្រសើរឡើងព្រមគ្នានោះដែរ ។

តែទោះជាយ៉ាងណាក៏ដោយ រាល់កិច្ចខិតខំប្រឹងប្រែងផ្នែកហិរញ្ញវត្ថុនៅតែបន្តជាប្រចាំ ហើយទិសដៅស្ថេរភាពហិរញ្ញវត្ថុនៅតែជាកត្តាអាទិភាព ។ ភាពផុយស្រួយ និងភាពទន់ខ្សោយនៃវិស័យហិរញ្ញវត្ថុនៅតែមាននៅប្រទេសកម្ពុជា និងនៅក្នុងវិស័យហិរញ្ញវត្ថុពិភពលោក ។ ដូច្នេះស្មារតីយល់ដឹង និងការជ្រួតជ្រាបបញ្ហាហិរញ្ញវត្ថុត្រូវតែបង្កើនឡើងពីសំណាក់សាធារណជន និងវិស័យហិរញ្ញវត្ថុផ្ទាល់ ដើម្បីងាយស្រួលកាត់បន្ថយហានិភ័យដែលបណ្តាលមកពីបញ្ហាហិរញ្ញវត្ថុក្នុងប្រព័ន្ធ ។ ដូច្នេះការបង្កើនតម្លាភាពក្នុង វិស័យធនាគារ គឺជា មធ្យោបាយមួយក្នុងការបង្កើនការយល់ដឹង និងការត្រៀមស្មារតីចំពោះបញ្ហាធនាគារ និងហិរញ្ញវត្ថុ ។ លើសពីនេះទៅទៀត ការបោះផ្សាយរបាយការណ៍ប្រចាំឆ្នាំលើកទី២របស់នាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាសង្ឃឹមថានឹងសំរេចបាននូវគោលបំណង និងការលើកកំពស់ស្មារតីនៃការយល់ដឹងនេះ ។

នៅទីបញ្ចប់ ខ្ញុំពិតជាសង្ឃឹមថារបាយការណ៍នេះនឹងបំរើអោយប្រិយ៍មិត្តអ្នកអានក្នុងការស្វែងយល់ស៊ីជំរៅពីស្ថានភាពហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ។

**សូមអរគុណ!**

# មាតិកា

**អារម្ភកថា**............................................................................................................i

**១. ប្រតិបត្តិការប្រព័ន្ធធនាគារ** ..................................................................................១

១.១ អនុបាតប្រុងប្រយ័ត្ន ..................................................................................៥

១.២ ការប្រឈមមុខមួយចំនួន ...........................................................................៦

**២. ការអភិវឌ្ឍន៍នៃវិស័យមីក្រូហិរញ្ញវត្ថុ** ..............................................................៨

**៣. សេចក្តីសន្និដ្ឋាន** ...................................................................................................១១

ឧបសម្ព័ន្ធទី ១ ធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា ឆ្នាំ ២០០៦

ឧបសម្ព័ន្ធទី ២ ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា

ឧបសម្ព័ន្ធទី ៣ ការត្រួតពិនិត្យធនាគារ និងកិច្ចព្រមព្រៀងបាសែល

# ១. ប្រតិបត្តិការប្រព័ន្ធធនាគារ

ក្នុងឆ្នាំ ២០០៦ ទ្រព្យសកម្មសរុបសុទ្ធរបស់ធនាគារទាំងអស់បានកើនឡើង ៣៨,៥% ពី ៥.៥៧០ ពាន់លានរៀល ដល់ ៧.៧១៦ ពាន់លានរៀល ។ ឥណទានសរុបសុទ្ធចំពោះវិស័យទាំងឡាយនៅក្នុងសេដ្ឋកិច្ចជាតិបានកើនឡើងរហូតដល់ ៤២% ហើយព្រមជាមួយគ្នានេះដែរប្រាក់បញ្ញើសរុបនៃវិស័យទាំងនោះ កើនឡើងជិតដល់ ៤៥% ។ ចំនួនអ្នកដាក់ប្រាក់ផ្ញើបានកើនឡើង ១៥,៩% និងចំនួនអ្នកខ្ចីបានកើនឡើង ២៤,៣% (គំនូសបំព្រួញទី១) ។ នៅក្នុងប្រទេសមួយ ដែលមានប្រជាជនត្រឹមតែ ៦% ប្រើប្រាស់ប្រព័ន្ធធនាគារផ្លូវការ តួលេខនេះ គឺជាការចង្អុលបង្ហាញដ៏សំខាន់នៃការកើនឡើងនូវជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋទៅលើប្រព័ន្ធធនាគារ ។

**គំនូសបំព្រួញទី១. ចំនួនអ្នកដាក់ប្រាក់បញ្ញើ និងអ្នកខ្ចីប្រាក់**







វត្តមានធនាគារដែលទទួលស្គាល់ជាអន្តរជាតិ ភាពជឿនលឿនក្នុងការផ្តល់សេវាកម្មជូនដល់អ្នកដាក់ប្រាក់ផ្ញើ និងការកើនឡើងនូវការឱ្យខ្ចី ក៏បានរួមចំណែកនៅក្នុងបំរែបំរួលជាវិជ្ជមាននេះផងដែរ ។ ឆ្នាំ ២០០៦ នេះជាឆ្នាំដែលត្រូវបានទទួលស្គាល់ថា ជាយុគសម័យដ៏ធំចម្បង នៃការវិវត្តន៍ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ATM និងការប្រើប្រាស់សេវាកម្មធនាគារ តាមរយៈអ៊ីនធើណេតនៅកម្ពុជា ។ ក្នុងឆ្នាំ ២០០៦ នេះ ATM ចំនួន ៦៩ បានដាក់អោយប្រើប្រាស់ ដែលបានធ្វើឱ្យចំនួនម៉ាស៊ីនសរុបកើនពី ១៧ ទៅ ៨៦ ។

យោងតាមផែនការអាជីវកម្មរបស់ធនាគារមួយចំនួន បរិមាណ ATM នឹងបន្តកើនឡើងថែមទៀត ។ ការរីករាលដាលនៃការប្រើប្រាស់សេវាកម្មធនាគារតាមរយៈអ៊ីនធើណេត ATM ឧបករណ៍ហិរញ្ញវត្ថុពាណិជ្ជកម្មថ្មីៗទៀត បានកត់សំគាល់អោយឃើញថាឆ្នាំ ២០០៦ គឺជាចំនុចរបត់នៅក្នុងការអភិវឌ្ឍន៍សេវាកម្មធនាគារនៅកម្ពុជា ។

## គំនូសបំព្រួញទី ២ : កំណើនឥណទាន និងប្រាក់បញ្ញើ




ក្នុងឆ្នាំ ២០០៦ ឥណទានសុទ្ធទៅអតិថិជនបានកើនឡើង ៤២% បើប្រៀបធៀបនឹងឆ្នាំ ២០០៥ ។ វិស័យដែលផ្តល់ការរីកចំរើនខ្លាំងជាងគេគឺ វិស័យកសិកម្ម ចំនួន ១១៤,៦% បន្តដោយអចលនទ្រព្យ និងការប្រើប្រាស់ជាសាធារណៈចំនួន ១០១,៩% និងការសាងសង់ចំនួន ៨៥,៦% ។ ឥណទានចំពោះវិស័យកសិកម្ម ដែលជាវិស័យមួយនៃវិស័យស្នូលនៃសេដ្ឋកិច្ចជាតិកម្ពុជា នៅតែបន្តកើនឡើងគួរឱ្យកត់សំគាល់ស្របតាមផែនការរបស់រាជរដ្ឋាភិបាល ។

## គំនូសបំព្រួញទី ៣ ឥណទានតាមវិស័យ




ជាមួយនឹងការកើនឡើងនូវសកម្មភាពឥណទាន ធនាគារបានខិតខំបំពេញតាមតំរូវការអាជីវកម្មរបស់ពួកគេ និងស្របពេលជាមួយគ្នានេះដែរ គោរពតាមបទប្បញ្ញត្តិនានា ។ សកម្មភាពនេះបានបង្ហាញអោយឃើញតាមរយៈ

ការកើនឡើងនូវដើមទុនបានបង់ជំរះចំនួន ១៧,៨% និងមូលនិធិផ្ទាល់សុទ្ធចំនួន ១៧,៩% ។ ក្នុងឆ្នាំ ២០០៦ ដើមទុនបានបង់ជំរះសរុបបានកើនឡើងពី ៩៥៨ ពាន់លានរៀល ទៅដល់ ១.១២៩ ពាន់លានរៀល ។

**គំនូសបំព្រួញទី ៤ : អនុបាតលទ្ធភាពចំណេញរបស់ធនាគារ**




ក្នុងឆ្នាំ ២០០៦ ប្រាក់ចំណេញសរុបបានកើនឡើងយ៉ាងឆាប់រហ័សចំនួន ១២៦% បើប្រៀបធៀបទៅនឹងឆ្នាំមុន ។ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម បានកើនឡើង ៧,៩% ក្នុងឆ្នាំ ២០០៥ និង ១៤,២% ក្នុងឆ្នាំ ២០០៦ ។ តួលេខនៃប្រាក់ចំណេញដ៏ខ្ពស់នេះដោយសារតែការកើនឡើង នូវចំណូលពីការប្រាក់ ៤៧,៣% និងការប្រមូលមកវិញនូវឥណទានមិនដំណើរការ ១៥,៧% បើប្រៀបធៀបទៅនឹងឆ្នាំមុន ។ ប្រាក់ចំណេញធៀបទៅនឹងមូលនិធិភាគទុនិក (ROE) បានកើនឡើងពី ៧,៨% ក្នុងឆ្នាំ ២០០៥ ដល់ ១៤,២% ក្នុងឆ្នាំ ២០០៦ ។ ប៉ុន្តែប្រាក់ចំណេញក្នុងឆ្នាំ ២០០៦ បានកើនឡើងដោយអន្លើ ដោយសារតែការប្រមូលមកវិញនូវឥណទានមិនដំណើរការមានចំនួនច្រើនគឺ ១៩,៦% នៃប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ ។ រចនាសម្ព័ន្ធនៃចំណូលមានភាពប្រសើរឡើង ដោយប្តូរពីការពឹងផ្អែកស្ទើរតែទាំងស្រុងលើចំណូលការប្រាក់ ទៅជាចំណូលកំរៃសេវា និងចំណូលផ្សេងៗទៀតយ៉ាងច្រើន ។ ទោះបីជាយ៉ាងណា ចំណាយប្រតិបត្តិការនៅតែជាបន្ទុកដ៏ធ្ងន់សំរាប់ធនាគារដែល មានចំនួន ៤៤% នៃចំណូលប្រតិបត្តិការដុល ។

ទ្រព្យសកម្មសរុបរបស់ធនាគារនៅកម្ពុជា គឺមានកំរិតដុល្លារូបនីយកម្មខ្ពស់ ដែលមានចំនួនរហូតដល់ ៩៧,៨% ចារឹកជារូបិយប័ណ្ណ ។ ទោះបីជាមានការខំប្រឹងប្រែងជំរុញអោយមានគណនីប្រាក់បញ្ញើជារៀលនៅក្នុងធនាគារជាច្រើនតាមរយៈការអោយអត្រាការប្រាក់ខ្ពស់ក៏ដោយ (ប្រាក់បញ្ញើសន្សំជារៀលជាមធ្យម ១,៨% ក្នុងមួយឆ្នាំធៀបជាមួយប្រាក់បញ្ញើសន្សំជាដុល្លារជាមធ្យមមានចំនួន ០,៩%) ក៏កំណើននៅមានកំរិតទាប (២៦%) ធៀបជាមួយគណនីប្រាក់បញ្ញើជាដុល្លា ដែលមានការកើនឡើងចំនួន ៤៦% ។ ដូចគ្នានេះដែរការឱ្យខ្ចីជារូបិយវត្ថុគឺ មានចំនួន ២,៨%នៃការឱ្យខ្ចីសរុប ។ ការឱ្យខ្ចីជារូបិយវត្ថុត្រឹមតែ ២,៨%នេះ បានបង្កើនការព្រួយបារម្ភដល់ធនាគារជាតិនៃកម្ពុជា ដែលជាអ្នកជំរុញអោយមានការប្រើប្រាស់រូបិយវត្ថុជាតិ ជាពិសេសនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុដែលត្រូវការទុនជារូបិយវត្ថុ ។

### គំនូសបំព្រួញទី ៥ : ឥណទានមិនដំណើរការ




នៅក្នុងឆ្នាំ ២០០៦ អនុបាតឥណទានមិនដំណើរការកើនឡើងពី ៧,៥% ទៅ ៩,៤% ដោយសារតែមានការកើនឡើងនៃឥណទានមិនដំណើរការ ។ ការកើនឡើងនេះ ស្របពេលជាមួយនឹងកំណើនជាបន្តបន្ទាប់ នៃការផ្តល់ឥណទានកាលពីប៉ុន្មានឆ្នាំកន្លងមក ។ ស្របគ្នាផងដែរ ជាមួយនឹងការពង្រឹងនីតិវិធីក្នុងការចាត់ថ្នាក់ឥណទានរបស់អ្នកត្រួតពិនិត្យ ដែលផ្អែកលើការវាយតំលៃស្ថានភាពរបស់អ្នកខ្ចី និងដោយមិនពឹងផ្អែកទាំងស្រុងទៅលើរយៈពេលនៃការហួសកាលកំណត់សងឡើយ ។ សំវិធានធនថយចុះ ១៦,៥% ក្នុងអំឡុងឆ្នាំ ២០០៥-២០០៦ ដោយសារតែការប្រមូលមកវិញនូវឥណទានមិនដំណើរការចំនួន ១៧,៩% ។

មានធនាគារខ្លះធ្វើចំណាត់ថ្នាក់សំពៀតឥណទានដោយផ្អែកតែលើរូបមន្តហួសកាលកំណត់សង និងមិនបានគិតពីស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីទេ ។ ជាទូទៅ ធនាគារដែលរងនូវការចុះត្រួតពិនិត្យដល់ទីកន្លែងនឹងមានចំណាត់ថ្នាក់ឥណទានត្រឹមត្រូវ ។ ចំណែកធនាគារមួយចំនួនទៀតធ្វើចំណាត់ថ្នាក់ឥណទានដោយផ្អែកទៅលើរយៈពេលហួសកាលកំណត់សងតែប៉ុណ្ណោះ ។ មូលហេតុនេះ គឺដោយសារមានការលំបាកក្នុងការទទួលនូវរបាយការណ៍ហិរញ្ញវត្ថុពីអ្នកខ្ចី ជាពិសេសរបាយការណ៍ហិរញ្ញវត្ថុដែលអាចជឿទុកចិត្តបាន ។ តាមរយៈការអង្កេតដែលបានធ្វើឡើងដោយធនាគារពិភពលោក ROSC ឆ្នាំ ២០០៦ (របាយការណ៍ស្តីពីការអង្កេតលើស្តង់ដារ និងក្រមគណនេយ្យនិងសវនកម្ម) បានបញ្ជាក់ផងដែរពីកង្វះខាតរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចជឿទុកចិត្តបានក្នុងសហគមន៍ជំនួញនៅកម្ពុជា ។ ដូច្នេះ ជាទូទៅធនាគារពឹងផ្អែកលើបទពិសោធន៍ដែលបានជួបប្រទះពីមុនជាមួយនឹងអតិថិជននីមួយៗតាមជាក់ស្តែង និងរយៈពេលហួស កំណត់សងរបស់គេសំរាប់ធ្វើចំណាត់ថ្នាក់ឥណទាន ។

## អនុបាតប្រុងប្រយ័ត្ន

### គំនូសបំព្រួញទី ៦ : អនុបាតសាធនភាព

អនុបាតសាធនភាព របស់ប្រព័ន្ធធនាគារនៅកម្ពុជា នៅតែមានកំរិតខ្ពស់ស្មើនឹង ២៦% ខ្ពស់ជាងកំរិតកំណត់របស់ធនាគារជាតិនៃកម្ពុជា ដែលស្មើនឹង ១៥% និងខ្ពស់ជាងអនុសាសន៍របស់គោលការណ៍គ្រឹះទីក្រុងបាសែលដែលតម្រូវត្រឹមតែ ៨% ។ និន្នាការថយចុះនេះដោយសារតែ ការកើនឡើងនៃការផ្តល់ឥណទាន[១] ។




### គំនូសបំព្រួញទី ៧ : ហានិភ័យធំៗ និង ឥណទានទៅសម្ព័ន្ធញាតិ

ក្នុងឆ្នាំ ២០០៦ ឥណទានមានហានិភ័យធំៗ និង ឥណទានទៅសម្ព័ន្ធញាតិមានការថយចុះយ៉ាងខ្លាំងធៀបនឹងឆ្នាំមុន ។ ការថយចុះនេះដោយសារតែមានការទូទាត់សងវិញ ពីការឱ្យខ្ចីទៅសម្ព័ន្ធញាតិ និង មានការផ្លាស់ប្តូររចនាសម្ព័ន្ធម្ចាស់ភាគហ៊ុនរបស់ធនាគារមួយចំនួន ។ ចំណែកការថយចុះនៃឥណទានទៅសម្ព័ន្ធញាតិ ដោយសារតែមានការផ្លាស់ប្តូរនូវវិធីសាស្ត្រគណនា ។ កន្លងមកឥណទានមាន




[១] *ឆ្លើយតបទៅនឹងការពង្រីកសកម្មភាពប្រតិបត្តិការរបស់ធនាគារ និងផ្អែកទៅលើការស្នើសុំរបស់វិស័យឯកជនក្នុងវេទិកាវិស័យឯកជនជាមួយរាជរដ្ឋាភិបាល ក្រោមអធិបតីភាពសម្តេចនាយករដ្ឋមន្ត្រី តម្រូវការលើអនុបាតភាពគ្រប់គ្រាន់នៃដើមទុនត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៥ និងកែប្រែពី ២០% មកត្រឹម ១៥% ក្នុងឆ្នាំ២០០៥ ។ នៅកម្ពុជា បទប្បញ្ញត្តិតម្រូវលើអនុបាតនេះមានកម្រិតខ្ពស់ជាងកំរិតស្តង់ដារអន្តរជាតិ ។ ប៉ុន្តែ វាមិនបានរឹតបន្តឹងហួសហេតុពេក ឬ មិនសមហេតុផលនៅក្នុងស្ថានភាពបច្ចុប្បន្នរបស់ប្រព័ន្ធធនាគារនៅកម្ពុជាទេ ។ បរិស្ថានច្បាប់ លទ្ធភាពប្រមូលមកវិញនូវវត្ថុបញ្ចាំ និងកង្វះរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មតម្រូវឱ្យមានការតម្រូវកាន់តែខ្ពស់ ។*

ហានិភ័យធំត្រូវបានគណនាផ្អែកលើកំរិតឥណទាន ដែលបានអនុម័ត (កំរិតអនុម័តដោយធនាគារជាតិនៃកម្ពុជា) ហើយហានិភ័យត្រូវបានថ្លឹង ១០០% ដោយមិនគិតពីប្រភេទនៃការប្រើប្រាស់ឥណទាន ។ អនុវត្តតាមបទប្បញ្ញត្តិបានធ្វើវិសោធនកម្មថ្មី ស្តីពីការត្រួតពិនិត្យហានិភ័យនៃឥណទានធំ ឥណទានទាំងអស់ត្រូវថ្លឹងហានិភ័យដោយផ្អែកលើប្រកាសស្តីពីអនុបាតសាធនភាព ដែលឆ្លុះបញ្ចាំងបានច្បាស់លាស់ជាងពីស្ថានភាពពិតប្រាកដរបស់ធនាគារ ។

តាមគំនូសបំព្រួញខាងលើ ឥណទានមួយចំនួននៅតែលើសគួរឱ្យកត់សំគាល់ ពីកំរិតកំណត់នៃឥណទានមានហានិភ័យធំ ។ ធនាគារជាតិនៃកម្ពុជាមានការលើកលែងមួយចំនួនកាលពីឆ្នាំមុនៗ ចំពោះហានិភ័យដែលមានការធានាពីធនាគារមេបានទទួលចំណាត់ចាត់ថ្នាក់អន្តរជាតិមួយគ្រប់គ្រាន់ ។ ការលើកឡើងពីឥណទានមានហានិភ័យធំនេះគឺដើម្បីឱ្យធនាគារទាំងអស់អនុវត្តឱ្យស្របតាមប្រកាសថ្មីនេះក្នុងរយៈពេលខ្លីខាងមុខ ។

(**កំណត់សំគាល់:** តួលេខឆ្នាំ ២០០៦ បានចាត់ទុកហានិភ័យគឺមានកំរិតកំណត់លើសពី ២០% តែប៉ុណ្ណោះ ។)

## ការប្រឈមមុខមួយចំនួន

កំណើនយ៉ាងរហ័សនៃប្រាក់បញ្ញើនិងឥណទាន បានជំរុញឱ្យធនាគារជាតិនៃកម្ពុជា បន្ថែមការយកចិត្តទុកដាក់លើការត្រួតពិនិត្យប្រុងប្រយ័ត្ន ដើម្បីធានាឱ្យបានប្រព័ន្ធហិរញ្ញវត្ថុរឹងមាំនិងមានសុវត្ថិភាព ។ អាជ្ញាធរត្រួតពិនិត្យផ្តោតការយកចិត្តទុកដាក់នូវចំណុចមួយចំនួនដូចខាងក្រោម :

**១- ឥណទានមិនដំណើរការ** : ការកើនឡើងនៃឥណទានមិនដំណើរការ គឺជាអ្វីដែលអ្នកត្រួតពិនិត្យត្រូវតែយកចិត្តទុកដាក់ ពីព្រោះតែភាគច្រើននៃឥណទានរបស់ធនាគារមានការធានាដោយវត្ថុបញ្ចាំជាអចលនទ្រព្យ ។ បច្ចុប្បន្ន កម្ពុជាប្រឈមនឹងបញ្ហាទីផ្សារអចលនទ្រព្យដែលមានតំម្លៃមិនស្ថិតថេរ ។ ដូច្នេះវានឹងមានការលំបាកសំរាប់ធនាគារក្នុងការប្រមូលឥណទានទាំងនោះមកវិញ ប្រសិនបើតំលៃរបស់អចលនទ្រព្យទាំងនោះធ្លាក់ចុះ ។ នៅពេលដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបានអនុវត្តពេញលេញ នោះនឹងធ្វើឱ្យឥណទានមិនដំណើរការអាចមានភាពប្រសើរឡើង ។ នាពេលបច្ចុប្បន្ន អ្នកត្រួតពិនិត្យនឹងបន្តការធ្វើចំណាត់ថ្នាក់ឥណទាន និងតម្រូវឱ្យធ្វើសំវិធានធនយ៉ាងតឹងរឹងបំផុត ។

**២- ឥណទានមានហានិភ័យធំ** : ធនាគារធំៗមួយចំនួននៅកម្ពុជាបានផ្តល់ឥណទានមានហានិភ័យធំលើសពីកំរិតកំណត់ ។ ទោះបីជាការផ្តល់ឥណទានទាំងនោះបានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា និងមានការធានាពីទីស្នាក់ការកណ្តាលរបស់ធនាគារក៏ដោយ ធនាគារជាតិនៃកម្ពុជានៅតែបន្តការយកចិត្តទុកដាក់តាមដានដដែល ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៦ ធនាគារជាតិនៃកម្ពុជាបានធ្វើវិសោធនកម្មលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យហានិភ័យ

ឥណទានធំ ដើម្បីពង្រឹងការត្រួតពិនិត្យបទប្បញ្ញត្តិប្រុងប្រយ័ត្នបន្ថែមទៀត ។

**៣- អនុបាតសាធនភាព** : អនុបាតសាធនភាពរបស់ប្រព័ន្ធធនាគារបានថយចុះចាប់តាំងពីប៉ុន្មានឆ្នាំមុន ទោះបីជាវាលើសពីកំរិតកំណត់ ១៥% ក៏ដោយ ។ និន្នាការថយចុះនេះ គឺបណ្តាលមកពីការកើនឡើងនៅក្នុងខ្ទង់ទ្រព្យសកម្មបានថ្លឹងហានិភ័យ ដូច្នេះអ្នកត្រួតពិនិត្យត្រូវយកចិត្តទុកដាក់បន្ថែមទៀត ។

**៤- ចំណូលពីទ្រព្យសកម្ម** : អនុបាតនេះបានកើនឡើងពី ១,៧៦% នៅក្នុងឆ្នាំ ២០០៥ ទៅ ២,៨៤% ក្នុង ឆ្នាំ ២០០៦ ។ ទោះបីជាយ៉ាងណា អត្រានេះនៅតែមានកំរិតទាបធៀបជាមួយនឹងប្រទេសជិតខាង ទោះជាកំរិតអត្រាការប្រាក់ខ្ពស់ក៏ដោយ ។ មូលហេតុ គឺបណ្តាលមកពីចំណាយប្រតិបត្តិការនៅកម្ពុជាមានកំរិតខ្ពស់ ហើយក៏ជាកត្តាមួយដែលធនាគារត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ។

**៥-ការប្រមូលផ្តុំ** : ៤៩% នៃប្រាក់បញ្ញើសរុប និង ៦១%នៃឥណទានសរុប ត្រូវបានប្រមូលផ្តុំក្នុងធនាគារធំៗចំនួនបី ។ តួលេខនេះបង្ហាញថា សុខភាពរបស់ប្រព័ន្ធធនាគារទាំងមូលពឹងផ្អែកលើធនាគារទាំងបីនេះ ។ គោលជំហររបស់ធនាគារជាតិនៃកម្ពុជាតែងតែអនុញ្ញាតឱ្យមានការប្រកួតប្រជែងនៅលើទីផ្សារដោយសេរីនិងយុត្តិធម៌។ ការឈានចូលដោយចំហររបស់ធនាគារថ្មីៗ អាចនឹងផ្លាស់ប្តូរនិន្នាការនេះជាយថាហេតុ និងអនុញ្ញាតឱ្យធនាគារល្អនៅស្ថិតថេរ ។

## ២. ការអភិវឌ្ឍនៃវិស័យមីក្រូហិរញ្ញវត្ថុ

ក្នុងឆ្នាំ ២០០៦ ធនាគារជាតិនៃកម្ពុជា បានរៀបចំសន្និសីទថ្នាក់ជាតិមួយនិងសន្និសីទតំបន់ចំនួនបីស្តីពីមីក្រូហិរញ្ញវត្ថុ ។ សន្និសីទនេះជាវេទិកាសាធារណៈសំរាប់ការពិភាក្សា ផ្លាស់ប្តូរយោបល់ និងបទពិសោធន៍គ្នាទៅវិញទៅមក ព្រមទាំងលើកឡើងពីអត្ថប្រយោជន៍ និងការប្រឈមមុខរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

**គំនូសបំព្រួញទី៨ : ឥណទាន និងប្រាក់បញ្ញើរបស់មីក្រូហិរញ្ញវត្ថុ**

សន្និសីទថ្នាក់ជាតិ និងសន្និសីទតំបន់នេះ ជាមធ្យោបាយមួយសំរាប់ជួយអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុពង្រឹងកិច្ចសហប្រតិបត្តិការទៅវិញទៅមក ដើម្បីជំរុញប្រសិទ្ធភាពនៃសេវាមីក្រូហិរញ្ញវត្ថុ និងលើកកំពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្រីក្រនៅជនបទ ។



បច្ចុប្បន្នមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណចំនួន ១៦ និងគ្រឹះស្ថានដែលចុះបញ្ជីជាប្រតិបត្តិករមីក្រូហិរញ្ញវត្ថុជនបទចំនួន ២៤ និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជីចំនួនប្រហែល ៦០ ។

នាដំណាច់ខែធ្នូ ឆ្នាំ ២០០៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណនិងគ្រឹះស្ថានដែលចុះបញ្ជីជាប្រតិបត្តិករមីក្រូហិរញ្ញវត្ថុជនបទមានសមតុល្យឥណទានសរុបចំនួន ៣៧៣ ពាន់លានរៀល ទៅអោយអ្នកខ្ចីប្រាក់ចំនួន ៤៧១.០២៦ នាក់ និង ប្រមូលប្រាក់បញ្ញើសរុប ១២ ពាន់លានរៀល ពីអ្នកដាក់ប្រាក់ផ្ញើចំនួន ១១៣.២៧៧ នាក់ ។ បើប្រៀបធៀបទៅនឹងខែ ធ្នូ ឆ្នាំ ២០០៥ ឥណទានសរុបបានកើនឡើង ៩០% ចំនួនអ្នកខ្ចីបានកើនឡើង ២៩% និងប្រាក់បញ្ញើបានកើនឡើង ៦១% ចំណែកចំនួនអ្នកដាក់ប្រាក់ផ្ញើបានថយចុះ ១៨% ។ ការថយចុះចំនួនអ្នកដាក់ប្រាក់ផ្ញើនេះ បណ្តាលមកពីការផ្លាស់ប្តូរនិន្នាការរបស់មីក្រូហិរញ្ញវត្ថុ ពីការទទួលយកប្រាក់បញ្ញើកាតព្វកិច្ចជាការធានាជំនួសឱ្យការទទួលទ្រព្យសម្បត្តិជាសម្ភារៈធានាវិញ ។

ការកើនឡើងនៃឥណទានចំពោះអតិថិជន គឺបណ្តាលមកពីការពង្រីកតំបន់ប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលចុះបញ្ជី មិនតែប៉ុណ្ណោះការយល់ដឹងរបស់សាធារណជន អំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងតំរូវការពីសាធារណជនលើមូលនិធិសំរាប់ពង្រីកអាជីវកម្មនៅតំបន់ជនបទក៏បានរួមចំណែកក្នុងការកើនឡើងនេះដែរ ។

ក្នុងឆ្នាំ ២០០៦ ក្រុមត្រួតពិនិត្យរបស់ការិយាល័យត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុ បានធ្វើការត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណចំនួន ១២ និង អង្គការក្រៅរដ្ឋាភិបាលចំនួន ២ ដែលបានដាក់ពាក្យសុំចុះបញ្ជីជាប្រតិបត្តិករមីក្រូហិរញ្ញវត្ថុជនបទ ។ ផ្អែកលើការត្រួតពិនិត្យ ភាពរឹងមាំនៃគ្រឹះស្ថានទាំងនោះជាទូទៅមានកំរិតល្អ ។

ទោះបីជាយ៉ាងណា គ្រឹះស្ថានទាំងនោះនៅតែត្រូវការមូលនិធិបន្ថែមដើម្បីពង្រីកប្រតិបត្តិការ ស្វែងរកបុគ្គលិកដែលមានគុណវុឌ្ឍិ និងស្មោះត្រង់ កែលំអរហេដ្ឋារចនាសម្ព័ន្ធ និង សហប្រតិបត្តិការជាមួយអាជ្ញាធរដែលពាក់ព័ន្ធ ។

**គំនូសបំព្រួញទី៩ៈ អនុបាតសាធនភាព**



យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវរក្សាអនុបាតសាធនភាពយ៉ាងតិចបំផុត ២០% ។ ក្នុងឆ្នាំ ២០០៤ ២០០៥ និង ២០០៦ អនុបាតសាធនភាពមានចំនួន ៧៣% ៥៦% និង ៤៤% ។ ការថយចុះនៃអនុបាតសាធនភាព បណ្តាលមកពីការកើនឡើងនៃការផ្តល់ឥណទាន ។ ទោះបីជាយ៉ាងណា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែត្រូវការទុនបន្ថែមទៀត ដើម្បីពង្រីកប្រតិបត្តិការរបស់ខ្លួន និងបំពេញតំរូវការរបស់អតិថិជន។

## គំនូសបំព្រួញទី១០_សាច់ប្រាក់ងាយស្រួល

ក្នុងឆ្នាំ ២០០៤ ២០០៥ និង ២០០៦ អនុបាតសាច់ប្រាក់ងាយស្រួលមានចំនួន ១៣.៨១០% ៣.៦៣០% និង ៤.០៥០% ។ យោងលើតួលេខនេះបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុមានសាច់ប្រាក់ងាយស្រួលខ្ពស់ ដោយសារទ្រព្យសកម្មភាគច្រើនរបស់គ្រឹះស្ថាន ជាទ្រព្យសកម្មរយៈពេលខ្លី ហើយម៉្យាងទៀត ដោយសារវិស័យមីក្រូហិរញ្ញវត្ថុមានប្រាក់បញ្ញើតិច ។




## គំនូសបំព្រួញទី១១_ និន្នាការនៃឥណទានមិនដំណើរការ

ឥណទានសរុបដែលបានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានការកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ ២០០៦។ វាបានកើនឡើងដល់ ៧៥% ក្នុងឆ្នាំ ២០០៦ ខណៈដែលឥណទានមិនដំណើរការថយចុះចំនួន២៣%។ អនុបាតបំណុលហួសកាលកំណត់សង នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៤ ២០០៥ និង ២០០៦ ស្មើនឹង ២% ០,៧% និង ០,៣% ។



## គំនូសបំព្រួញទី១២_ហានិភ័យធំៗ

ឥណទានមានហានិភ័យធំត្រូវបានកំណត់ន័យថា ជាឥណទានដល់អត្ថគាហកតែម្នាក់ដែលមានកំរិតលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនអនុញ្ញាតអោយមានឥណទានហានិភ័យធំនេះទេ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន ឥណទានហានិភ័យធំៗតែនៅក្នុងឆ្នាំ ២០០៥ និង ២០០៦ ដែលហានិភ័យធំៗនោះស្មើនឹង ០,៥% ក្នុងឆ្នាំ ២០០៥ នៃមូលនិធិផ្ទាល់សុទ្ធ និង ០,៩%ក្នុងឆ្នាំ ២០០៦ ។




## គំនូសបំព្រួញទី១៣_ឥណទានសម្ព័ន្ធញាតិ

អនុបាតឥណទានចំពោះសម្ព័ន្ធញាតិធៀបនឹងឥណទានសរុប និងឥណទានចំពោះសម្ព័ន្ធញាតិធៀបនឹងមូលនិធិផ្ទាល់សុទ្ធមានចំនួនតិចជាង ១% ។



## ៣. សេចក្តីសន្និដ្ឋាន

ប្រព័ន្ធធនាគារនៅឆ្នាំ ២០០៦ បានបង្ហាញពីភាពរីកចំរើនគួរអោយកត់សំគាល់ ។ ភាពរីកចំរើននេះមិនត្រឹមតែនៅវិស័យធនាគារពាណិជ្ជប៉ុណ្ណោះទេ ប៉ុន្តែវិស័យមីក្រូហិរញ្ញវត្ថុក៏មានភាពរីកចំរើនផងដែរ។ ឆ្នាំនៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានបញ្ចប់ទៅដោយភាពជោគជ័យយ៉ាងត្រចះត្រចង់ សំរាប់វិស័យមីក្រូហិរញ្ញវត្ថុ ដែលនាំមកជាមួយនូវកំណើនឥណទានចំនួន ៩០% នៅក្នុងតំបន់ជនបទ ។ សាធារណជន ជាពិសេសអ្នកដែលរស់នៅតាមបណ្តាខេត្តនានាចាប់ផ្តើមយល់ដឹងអំពីតួនាទីស្ថាប័នមីក្រូហិរញ្ញវត្ថុជាស្ថាប័នផ្តល់ឥណទានឯកជន ដែលមិនមែនជាអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ជំនួយដូចដែលធ្លាប់ដឹងឮដូចពីមុននោះទេ ។ ចំពោះផ្នែកធនាគារពាណិជ្ជ ទាំងប្រាក់បញ្ញើនិងឥណទានមានការកើនឡើងយ៉ាងខ្លាំង ដែលបញ្ជាក់អោយឃើញពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។

ការអភិវឌ្ឍទាំងនេះពិតជាមិនអាចទទួលបានទេ ប្រសិនបើមិនមានការចូលរួមពីកត្តាជាច្រើន ។ ជាបឋមគឺកត្តាស្ថេរភាពនយោបាយ។ ចាប់តាំងពីឆ្នាំ ១៩៩៧ មកស្ថានភាពនយោបាយនៅកម្ពុជា មិនធ្លាប់ដែលមានភាពស្ងប់ស្ងាត់ដូចបច្ចុប្បន្ននេះទេ ទោះបីជាមានការពន្យារពេលក្នុងការបង្កើតរាជរដ្ឋាភិបាលថ្មី ក្រោយការបោះឆ្នោតជាសកលនៅឆ្នាំ ២០០៣ ក៏ដោយ ។ កត្តាទី ២ គឺមូលដ្ឋានដ៏រឹងមាំនៃម៉ាក្រូសេដ្ឋកិច្ច ដែលក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះកំណើនផលិតផលក្នុងស្រុកសរុបមានជាមធ្យមប្រហែលជា៩%ក្នុងមួយឆ្នាំ។ កត្តាទី ៣ ពង្រឹងតួនាទីជាអាជ្ញាធរត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។ ការយកចិត្តទុកដាក់ត្រូវបានធ្វើឡើងតាមរយៈការពង្រឹងសមត្ថភាពអ្នកត្រួតពិនិត្យ ដើម្បីស្របតាមការផ្លាស់ប្តូរយ៉ាងលឿនរបស់វិស័យធនាគារ ។ ច្បាប់និងបទប្បញ្ញត្តិត្រូវបានកែសំរួលឡើងវិញ និងត្រូវបានបោះផ្សាយដើម្បីឆ្លើយតប និងដោះស្រាយការកើនឡើងនូវហានិភ័យរបស់ធនាគារ។ ទោះបីជាប្រព័ន្ធធនាគារមាននិន្នាការទទួលបានជោគជ័យក៏ដោយ ក៏ការយកចិត្តទុកដាក់លើភាពងាយទទួលរងគ្រោះដែលអាចកើតមានឡើងរបស់វិស័យធនាគារត្រូវតែមាន ។ ធនាគារជាតិនៃកម្ពុជាបានទទួលស្គាល់ពីតំរូវការបង្កើនសមត្ថភាពអ្នកត្រួតពិនិត្យនិងពង្រឹងការអនុវត្តបទប្បញ្ញត្តិបន្ថែមទៀត ដើម្បីឆ្លើយតបនិងដោះស្រាយនូវផលវិបាកដែលអាចកើតមាននាពេលខាងមុខ ។

# ឧបសម្ព័ន្ធទី ១

# ធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
# នៅកម្ពុជា ឆ្នាំ ២០០៦

( សូមមើលឧបសម្ព័ន្ធទី ១ នៅផ្នែកភាសាអង់គ្លេស)

# ឧបសម្ព័ន្ធទី ២

# ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
# នៅ កម្ពុជា

ចងក្រងដោយ **អ្នកស្រី សំបូរ រម្យមុនី**

**យោងតាម:** ឯកសារ របស់ធនាគារអភិវឌ្ឍន៍អាស៊ី

## ទស្សនៈរួមនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

បន្ទាប់ពីច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានអនុម័ត ធនាគារជាតិនៃកម្ពុជាបានរៀបចំកម្មវិធីកំណែទម្រង់ប្រព័ន្ធធនាគារ ដោយតម្រូវឱ្យគ្រឹះស្ថានធនាគារ ធ្វើការបង្កើនដើមទុនជាមូលដ្ឋានរបស់ខ្លួន និងគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ។ ជាលទ្ធផល នៅក្នុងខែវិច្ឆិកា ឆ្នាំ២000 មានធនាគារចំនួន ១៩ ត្រូវបានអនុញ្ញាតឱ្យបន្តប្រតិបត្តិការរបស់ខ្លួន ក្នុងខណៈដែលធនាគារ១២ទៀត ត្រូវបានដកហូតអាជ្ញាប័ណ្ណ និងរងនូវការជំរះបញ្ជី។ ជាលទ្ធផល ការធ្វើកំណែទម្រង់ប្រព័ន្ធធនាគារនេះបានបង្ហាញឱ្យឃើញថា អន្តរការីយកម្មធនាគារមានកំរិតទាប ដោយសារតែគុណភាពទ្រព្យសកម្មរបស់ធនាគារនៅមានកំរិត បណ្តាលពីឥណទានមិនដំណើរការខ្ពស់ ។

ចាប់តាំងពីឆ្នាំ ១៩៩៥ មកទល់ ឆ្នាំ២000 ទំហំឥណទានមិនដំណើរការក្នុងប្រព័ន្ធធនាគារមានការកើនឡើងគួរឱ្យកត់សម្គាល់ ។ កង្វះខាតព័ត៌មានដែលគួរឱ្យទុកចិត្តបានពីអ្នកខ្ចី បានធ្វើឱ្យប៉ះពាល់ដល់ការឱ្យខ្ចីរបស់ធនាគារ ។ មូលហេតុបណ្តាលមកពីអវត្តមាននៃការិយាល័យព័ត៌មានឥណទាន ឬការរៀបចំការចែករំលែកព័ត៌មានក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ។ ពេលដែលអ្នកខ្ចីប្រាក់ធនាគារ ឬក្រុមហ៊ុនមួយចំនួនធ្វើរបាយការណ៍ហិរញ្ញវត្ថុដោយគ្មានលក្ខណៈស្តង់ដារគណនេយ្យសំរាប់អនុវត្តទេ នោះធនាគារមិនអាចផ្តល់កម្ចីដោយផ្អែកលើការវិភាគលំហូរសាច់ប្រាក់បានទេ ដោយសារកង្វះព័ត៌មានហិរញ្ញវត្ថុរបស់អតិថិជនច្បាស់លាស់ ។ ជារួម ធនាគារត្រូវបង្ខំចិត្តឱ្យខ្ចីដោយផ្អែកលើប្រាតិភោគ ដែលជាប្រភពចំបងក្នុងការសងបំណុល ដោយគួបផ្សំជាមួយនឹងកង្វះខាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រតិបត្តិការ ដែលមានការធានាផងដែរ។

តាមបទពិសោធន៍របស់បណ្តាប្រទេសនានានៅលើសកលលោក បានលើកឡើងយ៉ាងមុតមាំថា ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន គឺពិតជាចាំបាច់ចំពោះប្រព័ន្ធហិរញ្ញវត្ថុ ដោយមិនគិតពីយន្តការនៃការចែករំលែកព័ត៌មានឥណទានធ្វើឡើងក្នុងលក្ខណៈជាឯកជនឬក៏ជាសារធារណៈ និង ព័ត៌មានដែលផ្សព្វផ្សាយនោះជាព័ត៌មានមានលក្ខណៈវិជ្ជមានឬអវិជ្ជមានក៏ដោយ ។ មិនត្រឹមតែធនាគារទេដែលត្រូវទទួលស្គាល់សារៈសំខាន់ក្នុងការផ្តល់ និង ប្រើប្រាស់ព័ត៌មានឥណទាន ប៉ុន្តែ អ្នកខ្ចីក៏ត្រូវទទួលស្គាល់ថា ឥរិយាបថនៃឥណទានរបស់ពួកគេនឹងត្រូវតាមដានដោយប្រព័ន្ធធនាគារ។ ជាមួយនឹងការបង្កើតអោយមានវប្បធម៌នៃការទទួលខុសត្រូវនៃការខ្ចី និងទំលាប់ក្នុងការប្រើប្រាស់ព័ត៌មានឥណទាន អ្នកខ្ចីល្អៗនឹងទទួលបានផលប្រយោជន៍ និងកាន់តែងាយស្រួលដើម្បីសុំហិរញ្ញប្បទាន ។

## ១. ការបង្កើត និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានឥណទាន

អវត្តមាននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា ត្រូវបានចាត់ទុកថាជាការខ្វះខាតធ្ងន់ធ្ងរក្នុងស្ថានភាព

ដែលការឱ្យខ្ចីមានហានិភ័យខ្ពស់ ។ ការគ្រប់គ្រងហានិភ័យឥណទានដ៏មានគុណភាពទាមទារឱ្យមានកត្តាជាគន្លឹះច្រើន ដូចជាព័ត៌មានឥណទាន ដោយហេតុនេះ ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានរកឃើញថាជាផ្នែកមួយដ៏សំខាន់សំរាប់កែទម្រង់ចក្ខុវិស័យនិងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកម្មវិធីអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ។

ជាជំហានដំបូង ធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារិកកម្ពុជាបានរិះរកវិធីសាស្ត្រសម្រាប់អភិវឌ្ឍការចែករំលែកព័ត៌មានឥណទាន ។ សមាគមធនាគារិកធ្លាប់បានបង្កើតឡើងនូវការសម្របសម្រួលក្រៅផ្លូវការនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលតាមរយៈនោះ អ្នកចង់សុំខ្ចីប្រាក់ត្រូវបង្ហាញនូវការជំពាក់ទាំងអស់របស់ខ្លួនកំពុងតែមានទៅដល់អ្នកឱ្យខ្ចី ជាមួយគ្នានោះ អ្នកឱ្យខ្ចីស្នើសុំព័ត៌មានឥណទានពីម្ចាស់បំណុលទាំងអស់របស់អ្នកសុំខ្ចី ដោយឈរលើមូលដ្ឋានស្ម័គ្រចិត្ត ។ ប៉ុន្តែវិធីសាស្ត្រនេះប្រកបទៅដោយចំណុចខ្សោយយ៉ាងច្រើន ក្នុងការផ្តល់ព័ត៌មានឥណទានទាន់ពេលវេលានិងគួរឱ្យទុកចិត្តបាន ។ លើសពីនេះទៀត វិធីសាស្ត្រនេះ អាចជាការល្មើស នឹងមាត្រាទី៤៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានកំណត់អំពីការសម្ងាត់វិជ្ជាជីវៈ ។ ពិនិត្យឃើញនូវចំណុចខ្វះខាតនេះទើបធនាគារជាតិនៃកម្ពុជា និង សមាគមធនាគារិកកម្ពុជា រួមជាមួយបណ្តាធនាគារពាណិជ្ជមួយចំនួនបានធ្វើការតាក់តែងអនុស្សរណៈស្តីអំពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ តាមរយៈការចុះកិច្ចព្រមព្រៀងលើអនុស្សរណៈនេះគឺជាចំណុចចាប់ផ្តើមលើការស្ថាបនាប្រព័ន្ធស្វ័យប្រវត្តិមួយ ដោយផ្អែកលើមូលដ្ឋានសាកល្បងជាមួយនឹងទិន្នន័យឯករាជ្យដែលប្រមូលព័ត៌មានពីអ្នកខ្ចីប្រាក់ថ្មី ប៉ុន្តែប្រព័ន្ធនោះនឹងមិនបានចង្អុលបង្ហាញអំពីឈ្មោះម្ចាស់បំណុល និងឈ្មោះធនាគារដែលបានផ្តល់ព័ត៌មានមកទេ ។

តាមរយៈក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ដំណើរការអភិវឌ្ឍប្រព័ន្ធនេះបានចាប់ផ្តើមនៅឆ្នាំ ២០០៤ ធនាគារជាតិនៃកម្ពុជានិងធនាគារជាសមាជិកបានចាប់ផ្តើមចុះហត្ថលេខាលើអនុស្សារណៈ បង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងគោលបំណងដើម្បីជម្រុញឱ្យសហគ្រាសធុនតូចនិងមធ្យមមានលទ្ធភាពទទួលប្រភពទុនពីប្រព័ន្ធធនាគារ ។ នៅដើមឆ្នាំ ២០០៥ ក្រុមការងាររៀបចំប្រព័ន្ធព័ត៌មានឥណទានមួយ ដឹកនាំដោយធនាគារជាតិនៃកម្ពុជា និងមានធនាគារទាំងអស់ជាសមាជិកត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការរៀបចំប្រព័ន្ធ និងដើម្បីធានាថា នីតិវិធី ប្រតិបត្តិការ និង សេចក្តីណែនាំការគ្រប់គ្រងអាចយកមកអនុវត្តបាននិងងាយស្រួលប្រើប្រាស់ ។ ដើម្បីបង្កើតប្រព័ន្ធនេះ សំខាន់បំផុតត្រូវមានការចូលរួមយ៉ាងសកម្មពីអ្នកដែលពាក់ព័ន្ធ ។ ទន្ទឹមនឹងនេះ ប្រព័ន្ធព័ត៌មានឥណទានអាចអនុញ្ញាតឱ្យធនាគារជាសមាជិកធ្វើការចែករំលែកព័ត៌មានឥណទានអវិជ្ជមានតាមរយៈប្រព័ន្ធគេហទំព័រ ដែលប្រព័ន្ធនេះមានមុខងារជាច្រើន ដូចជាការអង្កេត ការកែប្រែ ការចុះបញ្ជីព័ត៌មានឥណទាន ការធ្វើរបាយការណ៍ ស្ថិតិនៃការប្រើប្រាស់ និងស្ថានភាពនៃការតាមដាន ។



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបាន
ឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

ក្រុមការងារប្រព័ន្ធចែករំលែកព័តិមានឥណទានធ្វើការយ៉ាងជិតស្និទ្ធជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យព័តិមានឥណទាន និងក្របខ័ណ្ឌគតិយុត្តនិងបទបញ្ជាចាំបាច់ ។ ការប្រជុំក្រុមការងារប្រព័ន្ធព័តិមានឥណទានជាច្រើនលើកត្រូវបានរៀបចំឡើងនៅឆ្នាំ ២០០៥ និងនៅដើមឆ្នាំ ២០០៦ ដោយបានចូលរួមធ្វើការអង្កេតពីធនាគារជាសមាជិកទាំងអស់ ដើម្បីធានាថា ការរៀបចំប្រព័ន្ធដែលមានមូលដ្ឋានផ្អែកលើអ៊ិនធើណែតពិតជាឆ្លើយតបនឹងតំរូវការ និងងាយស្រួលប្រើប្រាស់។ ក្រុមការងារប្រព័ន្ធចែករំលែកព័តិមានឥណទាននេះ ដើរតួនាទីសំខាន់ក្នុងការធានាសុចរិតភាព ប្រតិបត្តិការ និងសារៈប្រយោជន៍នៃប្រព័ន្ធ។

បន្ថែមលើការបង្កើតមូលដ្ឋានទិន្នន័យនិងប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័តិមានឥណទាន វាក៏ជាការចាំបាច់ ក្នុងការបង្កើតក្របខ័ណ្ឌគតិយុត្តនិងបទបញ្ជា ដើម្បីផ្តល់សិទ្ធិអំណាចក្នុងការប្រើប្រាស់ប្រព័ន្ធនេះ ។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសលេខ ធ០០៦-០៧៣ប្រក ស្តីពីការប្រើប្រាស់ និងការការពារព័តិមានឥណទាន ដែលប្រកាសនេះមានគោលបំណងជំរុញឱ្យមានសកម្មភាពឥណទានមួយរឹងមាំ និងការគ្រប់គ្រងហានិភ័យពីគ្រឹះស្ថានទាំងអស់ដែលចូលរួមនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដោយអនុញ្ញាតឱ្យមានការបង្កើតភ្នាក់ងារប្រមូលព័តិមានឥណទានមជ្ឈការមួយ ដើម្បីប្រមូលនិងចែករំលែកព័តិមានឥណទានអវិជ្ជមានទាក់ទងនឹងអ្នកខ្ចីប្រាក់ធនាគារក្នុងចំណោម ធនាគារជាសមាជិក និងដោយការពារអោយមានការសំងាត់ពីព័តិមានរបស់អ្នកខ្ចីប្រាក់ពីការរំលោភលើព័តិមានឥណទាន។

នៅខែមិថុនា ឆ្នាំ២០០៦ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយនូវប្រកាសចំនួន ៣ បន្ថែមទៀត ទាក់ទងរចនាសម្ព័ន្ធចាត់តាំងសម្រាប់ធ្វើការគ្រប់គ្រងលើប្រព័ន្ធព័តិមានឥណទាន ។ ប្រកាសទាំងបីនេះរួមមាន : ប្រកាសស្តីពីការបង្កើតក្រុមប្រឹក្សាភិបាល ប្រកាសស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងប្រកាសស្តីពីការបង្កើតក្រុមប្រតិបត្តិនិងលេខាធិការដ្ឋាននៃប្រព័ន្ធចែករំលែកព័តិមានឥណទាន។ សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រងលើប្រព័ន្ធព័តិមានឥណទានមកពីតំណាងធនាគារជាតិនៃកម្ពុជា និងតំណាងធនាគារជាសមាជិក ។ ទន្ទឹមនឹងនេះប្រកាសស្តីពីដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័តិមានឥណទាន ក៏បានដាក់អនុវត្តផងដែរ ។ បន្ថែមលើសពីនេះទៀត អនុស្សារណៈរវាងធនាគារជាតិនៃកម្ពុជានិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្តីពីក្រុមប្រតិបត្តិសម្រាប់អនុវត្តប្រព័ន្ធបែងចែកព័តិមានឥណទានត្រូវបានរៀបចំឡើងនិងបានចុះហត្ថលេខា ដោយធនាគារជាសមាជិកនិងធនាគារជាតិនៃកម្ពុជា ។ គិតចាប់តាំងពីឆ្នាំ ២០០៤ រហូតមកដល់ខែមករា ឆ្នាំ ២០០៧ នេះ មានធនាគារពាណិជ្ជនិងឯកទេសចំនួន ១៨ បានស្ម័គ្រចិត្តចុះហត្ថលេខាលើអនុស្សារណៈជាមួយធនាគារជាតិនៃកម្ពុជា ។ គោលបំណងចំបង

របស់ក្រុមប្រតិបត្តិ គឺដើម្បីដាក់ចេញនូវវិធានសម្រាប់គំរោងសាកល្បងរយៈពេល ២ឆ្នាំ ដើម្បីកំណត់បែបបទដែលភ្ជាក់ងារប្រមូលព័ត៌មានឥណទានមជ្ឈការនិងធនាគារជាសមាជិក រួមទាំងគ្រឹះស្ថានហិរញ្ញវត្ថុជាសមាជិកផ្សេងៗទៀត ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសមាជិកភាព នឹងធ្វើការប្រមូល ចែកចាយ គ្រប់គ្រង និងប្រើប្រាស់ព័ត៌មានឥណទាន ដូច្នេះហើយ វាអាចទប់ស្កាត់នូវការប្រើប្រាស់មិនត្រឹមត្រូវនិងការរំលោភលើព័ត៌មានឥណទាន ។ ក្រោយពីបញ្ចប់ការចុះហត្ថលេខាលើអនុស្សារណៈនេះ នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៦ កន្លងមក ធនាគារជាតិនៃកម្ពុជាបានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី រៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាផ្លូវការ ក្រោមអធិបតីយភាពឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

ដោយបានបញ្ចប់និងសាកល្បងប្រព័ន្ធដែលផ្អែកលើអ៊ិនធើណែត និងការចេញផ្សាយក្របខ័ណ្ឌគតិយុត្តចាំបាច់បញ្ហាប្រឈមមុខ គឺត្រូវធានាប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ប្រព័ន្ធ។ ចាប់ពី ថ្ងៃទី១៤ ខែសីហា រហូតដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៦ ក្រុមប្រតិបត្តិប្រព័ន្ធព័ត៌មានឥណទានទទួលខុសត្រូវផ្នែកវែបសាយរួមសហការជាមួយអ្នកជំនួយបច្ចេកទេសធនាគារអភិវឌ្ឍន៍អាស៊ីបានចុះបង្រៀនផ្ទាល់ដល់ទីកន្លែងពីរបៀបចុះឈ្មោះ និងបញ្ចូលទិន្នន័យចូលទៅក្នុងប្រព័ន្ធ ។

នៅចុងខែកញ្ញា ឆ្នាំ២០០៦ នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវសារាចរណែនាំស្តីពីការប្រើប្រាស់និងការការពារប្រព័ន្ធចែកព័ត៌មានឥណទានដល់គ្រឹះស្ថានធនាគារជាសមាជិក ដើម្បីពន្យល់បន្ថែមអំពីវិធីសាស្ត្រនៃការផ្ញើរបាយការណ៍របស់ខ្លួនទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ ការអនុវត្តនេះនឹងធ្វើ ឈរលើមូលដ្ឋាននៃការសាកល្បងសម្រាប់រយៈពេលប៉ុន្មានខែដំបូងរហូតដល់ក្រុមប្រឹក្សាភិបាលប្រព័ន្ធព័ត៌មានឥណទានយល់ថា ប្រព័ន្ធនេះបានដំណើរការល្អហើយ និងថាមិនមានបញ្ហាពីការប្រតិបត្តិ។ ពេលណាក្រុមប្រឹក្សាភិបាលធ្វើការសំរេចលើការងារនេះ ក្រុមប្រតិបត្តិនឹងត្រូវអនុវត្តយ៉ាងពេញលេញ ។ ចាប់ពីថ្ងៃទី ២២ ខែ មករា ដល់ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ក្រុមប្រតិបត្តិធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការកែលំអរឱ្យកាន់តែប្រសើរឡើងនូវសូហ្វវែរ៍ (Software) ប្រព័ន្ធព័ត៌មានឥណទាន ។

## ២. ការអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានឥណទាននាពេលអនាគត

ដោយមានការសហការជាមួយធនាគារជាសមាជិក ធនាគារជាតិនៃកម្ពុជាបានចាត់ទុកថា ទោះបីជាការដាក់ឱ្យប្រើប្រាស់សាកល្បងប្រព័ន្ធព័ត៌មានឥណទានជាលើកដំបូង មិនទាន់មានភាពឥតខ្ចោះសោះនោះ ប៉ុន្តែជារួមគឺទទួលបានលទ្ធជោគជ័យ ។ ប៉ុន្តែព័ត៌មានមួយចំនួនទាក់ទិននឹងសំពៀតឥណទាន នៅតែមានការពិបាករក ដើម្បីបញ្ចូលនៅក្នុងប្រព័ន្ធព័ត៌មាន បើទោះជាមានការចូលរួមសហការពីបណ្តាធនាគារជាសមាជិកយ៉ាងណាក៏ដោយ ។ ក្រុមប្រតិបត្តិជាពិសេស ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធព័ត៌មានឥណទាននឹងជម្រុញលើកទឹកចិត្តដល់ធនាគារជាសមាជិក ក្នុងការចូលរួម


មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបាន
ឆ្លុះបញ្ចាំងពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

ផ្តល់ទិន្នន័យទាំងឥណទានវិជ្ជមាននិងអវិជ្ជមានកាន់តែច្រើនឡើងនាឆ្នាំ ២០០៧ នេះ ។ ទន្ទឹមនឹងនេះ ក្រុមប្រតិបត្តិប្រព័ន្ធព័ត៌មានឥណទាននឹងធ្វើការពិនិត្យមើលលទ្ធភាពបញ្ចូលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាសមាជិកក្នុងប្រព័ន្ធព័ត៌មានឥណទានផងដែរ ។ នៅពេលដែល ព័ត៌មានឥណទានកាន់តែមានភាពច្បាស់លាស់ និងមានចំនួនច្រើនឡើង កត្តានេះនឹងជួយសម្រួលដល់គ្រឹះស្ថានដែលជាសមាជិកធ្វើការវាយតម្លៃឥណទាន និងគ្រប់គ្រងលើហានិភ័យឥណទានរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ។ ព័ត៌មានឥណទានដែលច្បាស់លាស់នេះ កាន់តែមានប្រយោជន៍ក្នុងនោះអាចជួយផ្តល់ព័ត៌មានដល់អ្នកឱ្យខ្ចីអំពី ឯកជន ឬក្រុមហ៊ុន ដែលសុំខ្ចីក្នុងទំហំលើសពីសមត្ថភាពសងរបស់ខ្លួន ។ នៅពេលដែលការិយាល័យគ្រប់គ្រងលើប្រព័ន្ធព័ត៌មានឥណទាននេះមានភាពរឹងមាំ និងមានជំនឿទុកចិត្តពីគ្រឹះស្ថានជាសមាជិកធនាគារជាតិនៃកម្ពុជានឹងពិនិត្យមើលលើលទ្ធភាពក្នុងការផ្ទេរការិយាល័យទៅឱ្យឯកជនជាអ្នកគ្រប់គ្រងវិញ ។

ជារួម ព័ត៌មានឥណទានអំពីបំណុល និងការខកខានមិនបានសងបំណុលរបស់បុគ្គល និងក្រុមហ៊ុនជាធាតុចូលយ៉ាងសំខាន់ ដើម្បីឱ្យមានប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទានមួយប្រកបដោយគុណភាពខ្ពស់ និងត្រូវបានចាត់ទុកថាជាផ្នែកមួយដ៏សំខាន់និងចាំបាច់បំផុតនៅក្នុងដំណើរការវាយតម្លៃឥណទាន ។ ការទទួលបានព័ត៌មានឥណទាននាំឱ្យគ្រឹះស្ថានធនាគារផ្តល់ឥណទានប្រកបដោយទំនុកចិត្តខ្ពស់ និងកាត់បន្ថយបាននូវពេលវេលា ក៏ដូចជា ថវិកានៅក្នុងការវិភាគវាយតម្លៃឥណទាន និងអាចកាត់បន្ថយបាននូវហានិភ័យនៅក្នុងការឱ្យខ្ចីផងដែរ ។



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបាន
ឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

# ឧបសម្ព័ន្ធទី ៣

# ការត្រួតពិនិត្យធនាគារ និងកិច្ចព្រមព្រៀងបាសែល

**ចងក្រងដោយ៖ អ្នកស្រី ជា សិរី**

**ឯកសារយោង៖**

- គេហទំព័ររបស់ធនាគារសំរាប់ទូទាត់អន្តរជាតិ : www.bis.org
- ទិន្នន័យធនាគាររបស់នាយកដ្ឋានត្រួតពិនិត្យ

## ហេតុអ្វីត្រូវមានបទបញ្ញាប្រុងប្រយ័ត្នចំពោះធនាគារ?

វិស័យហិរញ្ញវត្ថុរបស់ជាតិមួយជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍន៍ជាតិរបស់ខ្លួន ។ ធនាគារដើរតួនាទីយ៉ាងសំខាន់និងជាពិសេសជាអន្តរការីយកម្មហិរញ្ញវត្ថុ ពោលគឺធ្វើកេណ្ឌប្រមូលមូលនិធិពីភ្នាក់ងារដែលមានសាច់ប្រាក់ងាយស្រួលលើស ទៅឱ្យភ្នាក់ងារដែលមានតំរូវការសាច់ប្រាក់ ។ Joseph Schumpeter ធ្វើការលើកឡើងបន្ថែមថា "ធនាគារិកមិនត្រឹមតែជាអន្តរការីប៉ុណ្ណោះទេ ... ធនាគារិកផ្តល់លទ្ធភាពឱ្យមនុស្សធ្វើការឆ្នៃប្រឌិតដើម្បីបំរើសង្គម" ។

វាជាការពិបាក ដើម្បីកេណ្ឌប្រមូលមូលនិធិដែលលើសនោះចូលមកក្នុងប្រព័ន្ធធនាគារ ។ ដូច្នេះធនាគារត្រូវប្រើប្រាស់យុទ្ធសាស្ត្រទីផ្សារ ដើម្បីទាក់ទាញមូលនិធិពីម្ចាស់ប្រាក់បញ្ញើ ដោយផ្តល់អត្រាការប្រាក់ខ្ពស់ និងផ្តល់ជាមធ្យោបាយទូទាត់ដ៏ទំនើបផ្សេងៗ (ដូចជា ប័ណ្ណឥណទាន មូលប្បទានប័ត្រ ប្រតិបត្តិការ "on-line" ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ។ល។) ។ ដូចគ្នាដែរ ធនាគារបង្កើតយុទ្ធសាស្ត្រទាក់ទាញអ្នកខ្ចីប្រាក់ ដើម្បីទាញផលចំណេញពីមូលនិធិដែលបានដាក់ផ្ញើទាំងអស់នោះ ។

សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់អាជ្ញាប័ណ្ណនិងការត្រួតពិនិត្យធនាគារត្រូវបានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ប្រកាសអោយប្រើនៅខែ មករា ឆ្នាំ ១៩៩៦ ត្រង់ជំពូកទី ៧ មាត្រាទី ៣៣ ដែលចែងថា "ធនាគារកណ្តាលនឹងទទួលខុសត្រូវទាំងស្រុងក្នុងការផ្តល់អាជ្ញាប័ណ្ណ ដកហូតអាជ្ញាប័ណ្ណ និងត្រួតពិនិត្យធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ" ។

ទោះបីកិច្ចការនេះហាក់ដូចជាងាយក៏ដោយ ប្រតិបត្តិការធនាគារមិនអាចប្រព្រឹត្តទៅដោយគ្មានហានិភ័យនោះទេ (រូបភាពទី១) ។ ដូច្នេះ អាជីវកម្មធនាគារជាអាជីវកម្មដែលអាជ្ញាធរបញ្ញត្តិករយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយហេតុថា :

- ធនាគារធ្វើអាជីវកម្មដោយប្រើប្រាស់ប្រភពមូលនិធិ ដែលជាប្រាក់បញ្ញើរបស់អតិថិជន (និងទឹកប្រាក់មួយភាគតូចពី មូលនិធិផ្ទាល់របស់ម្ចាស់ធនាគារ) ឬអាចនិយាយជាទូទៅបានថា ជាប្រាក់ដែលប្រមូលបានពីសាធារណជន ។ ការព្រួយបារម្ភរបស់អាជ្ញាធរត្រួតពិនិត្យ គឺធ្វើយ៉ាងណាឱ្យម្ចាស់ប្រាក់បញ្ញើមានលទ្ធភាពដកប្រាក់បញ្ញើសរុប របស់ពួកគេពីប្រព័ន្ធធនាគារវិញតាមតំរូវការ និងដើម្បីការពារកុំឱ្យធនាគារធ្វើការផ្ទេរហានិភ័យនៃជំនួញរបស់ពួកគេទៅឱយម្ចាស់ប្រាក់បញ្ញើ ។

- ការដួលរលំធនាគារអាចជះឥទ្ធិពលអាក្រក់ដ៏សំបើមចំពោះសេដ្ឋកិច្ចជាតិទាំងមូល ។ ពេលម្ចាស់ប្រាក់បញ្ញើបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធធនាគារ សេដ្ឋកិច្ចជាតិទាំងមូលត្រូវរងនូវការខូចខាត ដែលបណ្ដាលមកកង្វះប្រភពទុន (ផ្លូវការ) កិត្តិស័ព្ទរបស់ប្រទេសចំពោះវិនិយោគិនបរទេស ។ល។ នៅក្នុងសង្គមមួយដែលគេទទួលស្គាល់វិស័យធនាគារជាវិស័យមួយសំខាន់សំរាប់ប្រកបអាជីវកម្ម កង្វះនៃវិស័យនេះនៅក្នុងប្រទេសអាចរុញច្រានវិនិយោគិនអោយចាកចេញពីប្រទេស ។ ការឆ្លងតាមប្រព័ន្ធធនាគារ គឺជាមធ្យោបាយដ៏ល្អមួយសំរាប់អាជីវកម្មក្នុងការកាត់បន្ថយហានិភ័យសាច់ប្រាក់ងាយស្រួល សំរួលដល់ការធ្វើហិរញ្ញប្បទានដើម្បីពង្រីកអាជីវកម្ម ធ្វើឱ្យការដោះដូរទំនិញ និងសេវាកម្មប្រព្រឹត្តទៅដោយងាយស្រួល (តាមរយៈការផ្ដល់សេវាកម្មទូទាត់) ។ល។
- ការប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់ និងការធ្វើហិរញ្ញប្បទានដល់អំពើភេរវកម្ម អំពើពុករលួយ និងសកម្មភាពខុសច្បាប់ផ្សេងៗអាចប្រព្រឹត្តទៅបានដោយលំបាក ប្រសិនបើសាច់ប្រាក់ត្រូវបានចរាចរដោយសេរីនៅក្នុងសេដ្ឋកិច្ច ដោយមិនឆ្លងកាត់ប្រព័ន្ធធនាគារផ្លូវការ ។ សកម្មភាពឧក្រិដ្ឋផ្សេងៗអាចត្រូវបានកាត់បន្ថយមួយកំរិត ប្រសិនបើសាច់ប្រាក់ និងទ្រព្យសម្បត្តិមានតំលៃផ្សេងទៀតត្រូវបានរក្សាទុកនៅកន្លែងមានសុវត្ថិភាពដែលមានទាំងអត្ថប្រយោជន៍សេដ្ឋកិច្ចផង និងអត្ថប្រយោជន៍រូបវន្តផង ។
- ប្រព័ន្ធធនាគារគ្មានប្រសិទ្ធភាព អាចបង្កការលំបាកដល់ធនាគារកណ្ដាល ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុឱ្យបានសមស្រប ។ គោលដៅនៃការថែរក្សាស្ថេរភាពថ្លៃអាចនឹងមានភាពស្មុគស្មាញក្នុងការសំរេចឱ្យបាន ប្រសិនបើគ្មានប្រព័ន្ធធនាគារសមស្របមួយនោះទេ (ក្នុងចំណោមកត្តាផ្សេងទៀត) ។
- វត្តមាននៃប្រព័ន្ធធនាគារដោយសុវត្ថិភាពនិងភាពរឹងមាំ ជាសូចនាករដ៏ល្អ ស្ដីពីស្ថានភាពរបស់ប្រទេស។ ជាភស្តុតាង ការស្រាវជ្រាវហិរញ្ញវត្ថុដោយធនាគារពិភពលោក បានបង្ហាញថាប្រទេសដែលមានការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុប្រសើរ (ដែលមើលឃើញតាមរយៈការស៊ីជម្រៅនិងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ) នឹងមានការរីកចំរើនសេដ្ឋកិច្ចឆាប់រហ័ស ។



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបានឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

## រូបភាពទី ១ : ការបង្ហាញពីហានិភ័យ




ការទទួលយកហានិភ័យខ្ពស់អាចរារាំងដល់ការលូតលាស់នៃអាជីវកម្មធនាគារ ប៉ុន្តែវាក៏អាចបង្កនូវគ្រោះថ្នាក់ដល់ប្រាក់បញ្ញើរបស់អតិថិជនដែរ ប្រសិនបើហានិភ័យនោះក្លាយជាការពិត ។ នោះហើយជាពេលដែលត្រូវមានអាជ្ញាធរត្រួតពិនិត្យ ។ អាជ្ញាធរត្រួតពិនិត្យត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយហានិភ័យដែលធនាគារមានបំណងទទួលយក និងដើម្បីធ្វើអោយប្រាកដថា ធនាគារមិនបានផ្ទេរហានិភ័យនេះទៅឱ្យម្ចាស់ប្រាក់បញ្ញើ។ តាមរយៈច្បាប់ (ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) រាជរដ្ឋាភិបាលបានប្រគល់អោយធនាគារជាតិនៃកម្ពុជា (អាជ្ញាធរ ត្រួតពិនិត្យ) នូវសិទ្ធិអំណាចក្នុងការត្រួតពិនិត្យធនាគារដោយឯករាជ្យ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ហើយចាត់វិធានការចំពោះធនាគារដែលមិនបានអនុវត្តទៅតាមច្បាប់ ។

---



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបាន
ឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

ដោយសារវិបត្តិធនាគារអាចរីករាលដាលយ៉ាងលឿន ប្រទេសជាច្រើននៅលើពិភពលោកបានធ្វើការរួមគ្នាដើម្បីទប់ស្កាត់វិបត្តិទាំងនេះ ជាពិសេសប្រទេសដែលមាន ធនាគារធ្វើប្រតិបត្តិការអាជីវកម្មជាអន្តរជាតិ ។ នេះជាគោលដៅរបស់គណៈកម្មការបាសែល ដែលជាគណៈកម្មការដំបូងបង្កើតឡើងដើម្បីពិភាក្សាការងារត្រួតពិនិត្យធនាគារ ។

## កិច្ចព្រមព្រៀងបាសែល

គណកម្មការបាសែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧៤ ដោយបណ្តាធនាគារកណ្តាលប្រទេសធំទាំង ១០ ដែលហៅកាត់ថា G10 ។ គណកម្មការនេះត្រូវបានតំណាងដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់បណ្តាធនាគារកណ្តាល និងអាជ្ញាធរត្រួតពិនិត្យពីប្រទេសឧស្សាហកម្មទាំងនោះ ។ បច្ចុប្បន្នគណៈកម្មាធិការបាសែលមានសមាជិកចំនួន ១៣ គឺប្រទេស ប៊ែលហ្ស៊ិក កាណាដា អាល្លឺម៉ង់ បារាំង អ៊ីតាលី ជប៉ុន លុចសំបួរ ហូឡង់ដ៍ អេស្ពាញ សូអេត ស្វីស ចក្រភពអង់គ្លេស និង សហរដ្ឋអាមេរិក ។ គណៈកម្មការនេះបានរៀបចំបទដ្ឋាន ការណែនាំជាច្រើន ព្រមទាំងផ្តល់អនុសាសន៍អំពីការត្រួតពិនិត្យមានប្រសិទ្ធភាព ដោយសង្ឃឹមថាអាជ្ញាធរនីមួយៗនឹងចាត់វិធានការអនុវត្តការណែនាំទាំងនេះតាមនីតិវិធីច្បាប់ ឬផ្សេងទៀត ដែលស្របតាមប្រព័ន្ធនៃប្រទេសរៀងៗខ្លួន។

នៅក្នុងឆ្នាំ ១៩៨៨ គណៈកម្មការបាសែលបានសំរេចឧទ្ទេសនាមនូវប្រព័ន្ធវាស់វែងដើមទុនដែលទទួលស្គាល់ជាទូទៅថា ជាកិច្ចព្រមព្រៀងដើមទុនបាសែលឬ "បាសែល ១" ។ ប្រព័ន្ធវាស់វែងហានិភ័យឥណទានជាមួយនឹងស្តង់ដារដើមទុនអប្បបរមាចំនួន ៨% បានទាមទារនូវការអនុវត្តពេញលេញមុនចុងឆ្នាំ ១៩៩២ ។ ចាប់តាំងពីឆ្នាំ ១៩៨៨ គំរោងនេះត្រូវបានដាក់ឱ្យប្រើប្រាស់ មិនត្រឹមតែនៅក្នុងប្រទេសជាសមាជិកប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានអនុវត្តជាបន្តើរៗនៅតាមបណ្តាប្រទេសជាច្រើន ដែលមានធនាគារធ្វើប្រតិបត្តិការជាអន្តរជាតិ ។ នៅក្នុងខែមិថុនាឆ្នាំ ១៩៩៩ គណៈកម្មការបាសែល បានដាក់ចេញនូវសំណើស្តីពីការកែប្រែក្របខ័ណ្ឌនៃភាពគ្រប់គ្រាន់នៃដើមទុនឬបាសែល២ ។ ក្របខ័ណ្ឌដើមទុនថ្មី រួមមានមូលដ្ឋានគ្រឹះ ៣ យ៉ាងគឺ កាតព្វកិច្ចដើមទុនអប្បបរមាដែលព្យាយាមកំនត់ឡើងវិញនូវបទដ្ឋានជាស្តង់ដារ ដែលបានកំនត់នៅក្នុងកិច្ចព្រមព្រៀងឆ្នាំ ១៩៨៨ នីតិវិធីនៃការត្រួតពិនិត្យឡើងវិញរបស់អាជ្ញាធរត្រួតពិនិត្យ និងការប្រើប្រាស់នូវព័ត៌មានផ្សព្វផ្សាយជាសាធារណៈប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រឹងវិន័យកម្មទីផ្សារបន្ថែមលើការប្រឹងប្រែងត្រួតពិនិត្យ ។ បន្ទាប់ពីកិច្ចពិភាក្សាយ៉ាងទូលំទូលាយជាមួយធនាគារ វិស័យឧស្សាហកម្ម និងអាជ្ញាធរត្រួតពិនិត្យនៃក្រុមប្រទេសមិនមែនជាសមាជិកគណៈកម្មការបាសែល ក្របខ័ណ្ឌដែលបានកែប្រែត្រូវបានបោះផ្សាយនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៤ និងធ្វើបច្ចុប្បន្នកម្មនៅខែវិច្ឆិកា ឆ្នាំ ២០០៥ ។



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបានឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ គណៈកម្មការបាសែលបានព្យាយាមយ៉ាងខ្លាំងក្លា ដើម្បីផ្សព្វផ្សាយពីស្តង់ដារត្រួតពិនិត្យដ៏រឹងមាំនៅទូទាំងសកលលោក ។ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរត្រួតពិនិត្យ នៃក្រុមប្រទេសមិនមែនឧស្សាហកម្មទាំង ១០ គណៈកម្មការបាសែលបានបង្កើតឡើងនូវ *គោលការណ៍ស្នូលសំរាប់ ការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព (Core Principles)* នៅឆ្នាំ ១៩៩៧ ដែលផ្តល់នូវចក្ខុវិស័យសំរាប់ប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ។ គោលការណ៍ស្នូលទាំងនេះបង្កើតឡើង ដើម្បីឱ្យបណ្តាប្រទេស ទាំងឡាយអនុវត្តការត្រួតពិនិត្យធនាគារនៅក្នុងប្រទេសរបស់ខ្លួន ។

## គោលបំណងរបស់គោលការណ៍ស្នូលសំរាប់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព

គោលការណ៍ស្នូលជាគំរោងស្តង់ដាអប្បបរមាសំរាប់ការត្រួតពិនិត្យធនាគារដ៏រឹងមាំ និង អាចអនុវត្តបានជាទូទៅ ។ គណៈកម្មការបាសែលបានបង្កើតគោលការណ៍ស្នូលនិងវិធីសាស្ត្រ[១] ដើម្បីពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសកល ។ ភាពទន់ខ្សោយនៃប្រព័ន្ធធនាគាររបស់ប្រទេសមួយទោះបីជាប្រទេសកំពុងអភិវឌ្ឍក្តីឬបានអភិវឌ្ឍក្តីអាចគំរាមកំហែងដល់ស្ថេរភាពហិរញ្ញវត្ថុនៅក្នុងប្រទេសនិងអន្តរជាតិ ។ គណៈកម្មការបាសែលជឿជាក់ថា ការអនុវត្តន៍គោលការណ៍ស្នូលរបស់បណ្តាប្រទេសទាំងឡាយ ជាជំហានដ៏សំខាន់ឆ្ពោះទៅរកស្ថេរភាពហិរញ្ញវត្ថុក្នុងស្រុកនិងអន្តរជាតិ និងផ្តល់នូវមូលដ្ឋានដ៏ល្អសំរាប់ការអភិវឌ្ឍន៍ប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនាពេលខាងមុខ ។

ស្របទៅតាមវិធីសាស្ត្រនៃគោលការណ៍ស្នូល ប្រទេសជាច្រើនបានប្រើប្រាស់គោលការណ៍ស្នូលជាមូលដ្ឋានសំរាប់វាយតំលៃពីគុណភាពប្រព័ន្ធត្រួតពិនិត្យ និងសំរាប់កំណត់ការងារត្រូវធ្វើនាពេលអនាគតដើម្បីសំរេចបាននូវកំរិតជាមូលដ្ឋាននៃការត្រួតពិនិត្យដ៏រឹងមាំ ។ គោលការណ៍ស្នូលត្រូវបានមូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកប្រើប្រាស់នៅក្នុងបរិបថ កម្មវិធីវាយតំលៃប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីវាយតំលៃការអនុវត្តប្រព័ន្ធត្រួតពិនិត្យធនាគាររបស់បណ្តាប្រទេសទាំងឡាយ ។ យ៉ាងណាមិញ ចាប់តាំងពីឆ្នាំ ១៩៩៧ មកបំរែបំរួលសំខាន់ៗបានកើតឡើងនៅក្នុងបទប្បញ្ញត្តិធនាគារ បទពិសោធន៍ជាច្រើន ត្រូវបានទទួលតាមរយៈការអនុវត្តន៍គោលការណ៍ស្នូលនៅក្នុងប្រទេសនីមួយៗ និង ការយល់ដឹងនិងចន្លោះប្រហោងដែលមាននៅក្នុងបទប្បញ្ញត្តិត្រូវបានមើលឃើញយ៉ាងច្បាស់ ដែលជាទូទៅ នាំមកនូវការផ្សព្វផ្សាយថ្មីៗរបស់គណៈកម្មការបាសែល ។ ការវិវឌ្ឍន៍ទាំងនេះបានធ្វើអោយមានភាពចាំបាច់

---

[១] *បន្ថែមទៅលើគោលការណ៍ស្នូលទាំងនោះ នៅក្នុងឯកសារវិធីសាស្ត្រគោលការណ៍ស្នូល គណៈកម្មការបាសែលបានបង្កើតឡើងនូវនីតិវិធីកាន់តែលំអិតសំរាប់វាយតំលៃពីភាពអនុលោមទៅតាមគោលការណ៍នីមួយៗ បោះផ្សាយដំបូងនៅក្នុងឆ្នាំ ១៩៩៩ និងបានធ្វើបច្ចុប្បន្នកម្មដែលជាផ្នែកមួយនៃការត្រួតពិនិត្យឡើងវិញ ។*

ក្នុងការបច្ចុប្បន្នកម្មគោលការណ៍ស្នូល (នាខែតុលា ឆ្នាំ ២០០៦ ការធ្វើបច្ចុប្បន្នកម្មគោលការណ៍ស្នូលមួយត្រូវបានផ្សព្វផ្សាយ) និងវិធីសាស្ត្រវាយតំលៃដែលពាក់ព័ន្ធ ។ គោលការណ៍ស្នូលរបស់បាសែលបានកំនត់គោលការណ៍ចំនួន ២៥ ដែលចាំបាច់ សំរាប់ប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ។ គោលការណ៍ទាំងនោះទាក់ទងទៅនឹង :

## គោលការណ៍ទី ១ : គោលបំណង ឯករាជ្យភាព អំណាច តម្លាភាព និងកិច្ចសហប្រតិបត្តិការ

ប្រព័ន្ធត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ត្រូវមានការទទួលខុសត្រូវ និងគោលបំណងច្បាស់លាស់ សំរាប់អាជ្ញាធរនីមួយៗដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យធនាគារ ។ អាជ្ញាធរនីមួយៗត្រូវមានឯករាជ្យភាពខាងផ្នែកប្រតិបត្តិការ ដំណើរការដោយតម្លាភាព អភិបាលកិច្ចល្អនិងធនធានគ្រប់គ្រាន់ និងទទួលខុសត្រូវរាល់ការបំពេញភារៈកិច្ចរបស់ខ្លួន ។ ក្របខ័ណ្ឌច្បាប់ដ៏សមស្របសំរាប់ការត្រួតពិនិត្យធនាគារជាការចាំបាច់ផងដែរ ដែលរួមមានការផ្តល់សិទ្ធិអំណាចក្នុងការបង្កើតធនាគារនិងការត្រួតពិនិត្យជាប្រចាំ សិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មខាងវិន័យក្នុងករណីមិនគោរពតាមច្បាប់និងបទប្បញ្ញត្តិដែលនាំឱ្យប៉ះប៉ាល់ដល់ភាពរឹងមាំនិងសុវត្ថិភាព និងការការពារតាមផ្លូវច្បាប់ដល់មន្ត្រីត្រួតពិនិត្យ ។ គោលការណ៍សំរាប់បែងចែកព័ត៌មានរវាងមន្ត្រីត្រួតពិនិត្យ និងការរក្សាការសំងាត់នៃព័ត៌មានទាំងនោះគួររៀបចំអោយមានឡើង ។

## គោលការណ៍ទី ២ : សកម្មភាពដែលបានអនុញ្ញាត

សកម្មភាពដែលបានអនុញ្ញាតចំពោះគ្រឹះស្ថានដែលមានអាជ្ញាប័ណ្ណ ជាធនាគារដែលត្រូវទទួលរងការត្រួតពិនិត្យត្រូវតែបញ្ជាក់ឱ្យបានច្បាស់ ហើយការប្រើប្រាស់ពាក្យថា "ធនាគារ" ជានាមសញ្ញាត្រូវធ្វើការត្រួតពិនិត្យតាមដែលអាចធ្វើបាន ។

## គោលការណ៍ទី ៣ : លក្ខណៈវិនិច្ឆ័យនៃអាជ្ញាប័ណ្ណ

អាជ្ញាធរផ្តល់អាជ្ញាប័ណ្ណត្រូវមានសិទ្ធិអំណាចក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យនិងបដិសេធលើការដាក់ពាក្យសំរាប់ការបង្កើតដែលមិនសមស្របទៅនឹងស្តង់ដារដែលបានបង្កើត ។ ដំណើរការផ្តល់អាជ្ញាប័ណ្ណជាអប្បបរមាគួរតែមានការវាយតំលៃពីរចនាសម្ព័ន្ធនៃម្ចាស់ភាគហ៊ុន អភិបាលកិច្ចរបស់ធនាគារ និងក្រុមសម្ព័ន្ធញាតិទាំងឡាយ ដូចជា ភាពសមស្របនិងទ្រព្យសម្បត្តិនៃសមាជិកក្រុមប្រឹក្សាភិបាលនិងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ យុទ្ធសាស្ត្រនិងផែនការប្រតិបត្តិការ ការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យ និងការព្យាករណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយរួមបញ្ចូលទាំងដើមទុនមូលដ្ឋានផងដែរ ។ ប្រសិនបើភាគទុនិកឬក្រុមហ៊ុនដែលដាក់ពាក្យសុំជាធនាគារបរទេស ការអនុញ្ញាតិជាមុនពីស្ថាប័នត្រួតពិនិត្យនៅប្រទេសដើមត្រូវយកមកពិចារណា ។


មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបានឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

## គោលការណ៍ទី ៤ : ការផ្ទេរភាគហ៊ុនសំខាន់

ភ្នាក់ងារត្រួតពិនិត្យត្រូវមានអំណាចក្នុងការពិនិត្យមើល និងបដិសេធចំពោះសំណើទាំងឡាយណាដែលធ្វើការផ្ទេរភាគហ៊ុនសំខាន់ឬការគ្រប់គ្រងអត្ថប្រយោជន៍ដោយផ្ទាល់និងដោយប្រយោល នៅក្នុងធនាគារដែលមានស្រាប់ទៅភាគីផ្សេងទៀត។

## គោលការណ៍ទី ៥ : ការកាន់កាប់ចំបងៗ

ភ្នាក់ងារត្រួតពិនិត្យត្រូវមានសិទ្ធិអំណាចក្នុងការរៀបចំលក្ខខណ្ឌ ដើម្បីពិនិត្យមើលនូវការកាន់កាប់ចំបងៗ ឬការវិនិយោគដោយធនាគារ ដូចជាការបង្កើតប្រតិបត្តិការឆ្លងប្រទេស និងបញ្ជាក់ថាសាជីវកម្មសម្ព័ន្ធញាតិ ឬសាជីវកម្មស្ថិតនៅក្រោមរចនាសម្ព័ន្ធមិនបានជំរុញអោយធនាគារទទួលរងហានិភ័យហួសកំណត់ ឬ រារាំងដល់ការត្រួតពិនិត្យដ៏មានប្រសិទ្ធិភាពទេ ។

## គោលការណ៍ទី ៦ : ភាពគ្រប់គ្រាន់នៃដើមទុន

ភ្នាក់ងារត្រួតពិនិត្យត្រូវកំណត់ដោយប្រុងប្រយ័ត្ននិងសមស្រប នូវភាពគ្រប់គ្រាន់នៃដើមទុនអប្បបរមាតំរូវឱ្យធនាគារមាន ដែលឆ្លុះបញ្ចាំងពីហានិភ័យដែលធនាគារទទួលយក និងត្រូវកំណត់សមាសធាតុនៃដើមទុនដោយត្រូវស្វែងយល់ពីលទ្ធភាពស្រូបយកការខាតបង់ ។ ចំពោះធនាគារដែលធ្វើប្រតិបត្តិការជាអន្តរជាតិ ការកំណត់តំរូវការទាំងនេះមិនត្រូវតិចជាងអ្វីដែលបានបង្កើតឡើងនៅក្នុងតំរូវការបច្ចុប្បន្នរបស់បាសែលទេ។

## គោលការណ៍ទី ៧ : ដំណើរការគ្រប់គ្រងហានិភ័យ

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារនិងក្រុមសម្ព័ន្ធធនាគារ មានរួចជាស្រេចនូវគោលការណ៍ គ្រប់គ្រងហានិភ័យដ៏សមស្របមួយ (រួមទាំងការត្រួតពិនិត្យសំណាក់ក្រុមប្រឹក្សានិងអ្នកគ្រប់គ្រងជាន់ខ្ពស់) ក្នុងការកំណត់ វាយតំលៃ ត្រួតពិនិត្យ និងតាមដាន ឬកាត់បន្ថយហានិភ័យសំខាន់ៗ និងដើម្បីប៉ាន់ ប្រមាណពីភាពគ្រប់គ្រាន់នៃដើមទុនទាំងមូលធៀបទៅនឹងប្រវត្តិហានិភ័យរបស់ពួកគេ។ ដំណើរការនេះត្រូវស៊ីសង្វាក់ជា មួយនឹងទំហំ និងភាពស្មុគស្មាញរបស់ស្ថាប័ន។

## គោលការណ៍ទី ៨ : ហានិភ័យឥណទាន

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលការណ៍គ្រប់គ្រងហានិភ័យឥណទានដែលពិចារណា ទៅលើប្រវត្តិហានិភ័យរបស់ស្ថាប័ន ដោយគោលការណ៍និងដំណើរការប្រុងប្រយ័ត្ន ដើម្បីកំណត់ វាស់វែង ត្រួតពិនិត្យ និងតាមដានហានិភ័យឥណទាន (រួមទាំងហានិភ័យសមាសភាគី) ។ ប្រការនេះអាចរួមបញ្ចូល

ការផ្តល់ឥណទាន និងការវិនិយោគ ការវិភាគគុណភាពឥណទាននិងការវិនិយោគនោះ និងការគ្រប់គ្រងជាប្រចាំលើសំពៀតឥណទាន និង ការវិនិយោគ ។

## គោលការណ៍ទី ៩ : ទ្រព្យសកម្មដែលមានបញ្ហា សំវិធានធន និងទុនបំរុង

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារបានបង្កើតនិងអនុវត្តអនុលោមទៅតាមគោលការណ៍ និងនីតិវិធីរបស់ខ្លួនដើម្បីគ្រប់គ្រងទ្រព្យសកម្មដែលមានបញ្ហា និងវាយតំលៃលើភាពគ្រប់គ្រាន់នៃសំវិធានធន និងទុនបំរុង ។

## គោលការណ៍ទី ១០ : ការកំណត់ហានិភ័យធំៗ

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលការណ៍ និងនីតិវិធីដែលអាចអោយអ្នកគ្រប់គ្រងធ្វើការកំណត់ និងគ្រប់គ្រងការប្រមូលផ្តុំនៅក្នុងសំពៀតឥណទាន ហើយភ្នាក់ងារត្រួតពិនិត្យត្រូវកំណត់ក៏រិតជាបទបញ្ជាប្រុងប្រយ័ត្ន ដើម្បីរារាំងហានិភ័យធនាគារចំពោះសមាសភាគីតែមួយ ឬ សមាសភាគីច្រើន ដែលមានទំនាក់ទំនងគ្នា ។

## គោលការណ៍ទី ១១ : ហានិភ័យឥណទានទៅសម្ព័ន្ធញាតិលើស

ដើម្បីទប់ស្កាត់ផលលំបាកដែលកើតឡើងពីហានិភ័យឥណទានសម្ព័ន្ធញាតិ (ទាំងក្នុងតារាងតុល្យការនិងក្រៅតារាងតុល្យការ) និងដើម្បីបង្ហាញពីទំនាស់ផលប្រយោជន៏ ភ្នាក់ងារត្រួតពិនិត្យត្រូវកំណត់តំរូវការរួចជាស្រេចដែលធនាគារអាចមានហានិភ័យជាមួយក្រុមហ៊ុនសម្ព័ន្ធញាតិនិងឯកត្តជននីមួយៗទៅតាមករណីជាក់ស្តែង ដោយធ្វើការត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាព លើកឡើងជំហានសមស្របដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យ ហើយការលុបចោលឥណទានសម្ព័ន្ធញាតិត្រូវធ្វើឡើងទៅតាមគោលការណ៍និងដំណើរការជាស្តង់ដារ ។

## គោលការណ៍ទី ១២ : ហានិភ័យប្រទេសនិងហានិភ័យនៃការផ្ទេរ

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលការណ៍និងដំណើរការសមស្របសំរាប់កំណត់ វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យប្រទេសនិងហានិភ័យនៃការផ្ទេរនៅក្នុងការផ្តល់កម្ចី និងសកម្មភាពវិនិយោគជាអន្តរជាតិ និងសំរាប់រក្សាភាពគ្រប់គ្រាន់នៃសំវិធានធននិងទុនបំរុង ចំពោះហានិភ័យទាំងនោះ ។

## គោលការណ៍ទី ១៣ : ហានិភ័យទីផ្សារ

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលការណ៍និងនីតិវិធីដែលអាច



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបានឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

កំណត់ វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យទីផ្សារអោយបានត្រឹមត្រូវ ។ ភ្នាក់ងារត្រួតពិនិត្យត្រូវមានសិទ្ធិអំណាចក្នុងការកំណត់កំរិតជាក់លាក់ និង/ឬតំរូវការដើមទុនជាក់លាក់ចំពោះហានិភ័យទីផ្សារប្រសិន បើអាចធ្វើបាន ។

## គោលការណ៍ទី ១៤ : ហានិភ័យសាច់ប្រាក់ងាយស្រួល

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់ងាយស្រួលដែលពិចារណាអំពីប្រវត្តិហានិភ័យរបស់ស្ថាប័ន ហើយមានគោលនយោបាយនិងនីតិវិធីប្រុងប្រយ័ត្ន ដើម្បី កំណត់ វាយតំលៃ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល និងដើម្បីគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ជាប្រចាំ។ ភ្នាក់ងារត្រួតពិនិត្យតំរូវឱ្យធនាគារមានផែនការយថាហេតុ សំរាប់ដោះស្រាយបញ្ហាសាច់ប្រាក់ងាយស្រួល។

## គោលការណ៍ទី ១៥ : ហានិភ័យប្រតិបត្តិការ

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលការណ៍និងនីតិវិធីគ្រប់គ្រងហានិភ័យដើម្បីកំណត់ ប៉ាន់ប្រមាណ ត្រួតពិនិត្យ និងកាត់បន្ថយហានិភ័យប្រតិបត្តិការ។ គោលការណ៍និងដំណើរការទាំងនោះត្រូវមានភាពសមស្របជាមួយនឹងទំហំ និងភាពស្មុគស្មាញរបស់ធនាគារ ។

## គោលការណ៍ទី ១៦ : ហានិភ័យអត្រាការប្រាក់

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានប្រព័ន្ធដ៏មានប្រសិទ្ធភាពរួចជាស្រេចដើម្បីកំណត់ វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យអត្រាការប្រាក់នៅក្នុងធនាគាររួមទាំងយុទ្ធសាស្ត្រដ៏ល្អដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងបានអនុវត្តន៍ដោយគណៈគ្រប់គ្រងជាន់ខ្ពស់ សមស្របទៅនឹងទំហំ និងភាពស្មុគស្មាញរបស់ពួកគេ។

## គោលការណ៍ទី ១៧ : ការត្រួតពិនិត្យផ្ទៃក្នុងនិងសាវនកម្ម

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរួចជាស្រេចដែលសមស្របទៅនឹងទំហំ និងភាពស្មុគស្មាញរបស់អាជីវកម្មធនាគារ ។ ការត្រួតពិនិត្យផ្ទៃក្នុងគួររួមបញ្ចូលការចាត់ចែងច្បាស់លាស់សំរាប់ផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវ បែងចែកមុខងារដែលទាក់ទងជាមួយការប្រតិបត្តិរបស់ធនាគារ ការផ្តល់មូលនិធិ ការចុះបញ្ជីគណនេយ្យសំរាប់ទ្រព្យសកម្មនិងទ្រព្យអកម្ម ការផ្ទៀងផ្ទាត់ដំណើរការទាំងនេះ ការការពារទ្រព្យសកម្មរបស់ធនាគារ និងឯករាជ្យភាពនៃការត្រួតពិនិត្យផ្ទៃក្នុងនិងមុខងារអនុលោមដ៏សមស្រប ដើម្បីសាកល្បងពីភាពត្រឹមត្រូវទៅតាមប្រព័ន្ធត្រួតពិនិត្យទាំងនោះ ក៏ដូចជាការអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិ ។

## គោលការណ៍ទី ១៨ : ការបំពានលើសេវាកម្មហិរញ្ញវត្ថុ

ភ្នាក់ងារត្រួតពិនិត្យត្រូវបានទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលនយោបាយនិងវិធីសាស្ត្រគ្រប់គ្រាន់រួចជាស្រេចរាប់បញ្ចូលទាំងបញ្ញត្តិស្តីពី "គោលការណ៍ស្គាល់អតិថិជន " ដែលជំរុញឱ្យមានក្រមសីលធម៌និងស្តង់ដារវិជ្ជាជីវៈខ្ពស់ខាងវិស័យហិរញ្ញវត្ថុ និងទប់ស្កាត់មិនឱ្យមានសកម្មភាពឧក្រិដ្ឋកម្មឆ្លងកាត់ធនាគារ ទោះជា ចេតនាឬអចេតនាក៏ដោយ ។

## គោលការណ៍ទី ១៩ : វិធីត្រួតពិនិត្យ

ប្រព័ន្ធត្រួតពិនិត្យធនាគារដ៏មានប្រសិទ្ធភាពតំរូវឱ្យភ្នាក់ងារត្រួតពិនិត្យ យល់អោយច្បាស់នូវប្រតិបត្តិការរបស់ធនាគារនីមួយៗ ធនាគារជាក្រុម និងពីប្រព័ន្ធធនាគារទាំងមូល ដោយផ្តោតលើសុវត្ថិភាពនិងភាពរឹងមាំ និងស្ថេរភាពរបស់ប្រព័ន្ធធនាគារ ។

## គោលការណ៍ទី ២០ : បច្ចេកទេសត្រួតពិនិត្យ

ប្រព័ន្ធត្រួតពិនិត្យធនាគារដ៏មានប្រសិទ្ធភាព តំរូវអោយមានការត្រួតពិនិត្យលើឯកសារនិងការត្រួតពិនិត្យដល់ទីកន្លែង និងត្រូវទាក់ទងជាប្រចាំជាមួយគណៈគ្រប់គ្រងធនាគារ ។

## គោលការណ៍ទី ២១ : របាយការណ៍ត្រួតពិនិត្យ

ភ្នាក់ងារត្រួតពិនិត្យត្រូវមានមធ្យោបាយក្នុងការប្រមូល ធ្វើវិវេចនា និងវិភាគរបាយការណ៍ប្រុងប្រយ័ត្ន និងទិន្នន័យស្ថិតិពីធនាគារដោយឈរលើមូលដ្ឋានរួមនិងដោយឡែក និងត្រូវមានមធ្យោបាយផ្ទៀងផ្ទាត់របាយការណ៍ទាំងនេះដោយឯករាជ្យ តាមរយៈការចុះត្រួតពិនិត្យដល់ទីកន្លែងឬការប្រើប្រាស់អ្នកជំនាញពីខាងក្រៅ ។

## គោលការណ៍ទី ២២ : គណនេយ្យកម្មនិងការបង្ហាញ

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារនីមួយៗបានរក្សាទុករបាយការណ៍គ្រប់គ្រាន់ ដែលរៀបចំអនុលោមទៅតាមគោលការណ៍គណនេយ្យនិងការអនុវត្តដែលទទួលស្គាល់ដោយអន្តរជាតិ និងបោះផ្សាយជាប្រចាំនូវព័ត៌មានដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុ និងប្រាក់ចំណេញរបស់ខ្លួន ។

## គោលការណ៍ទី ២៣ : សិទ្ធិអំណាចក្នុងការកែតំរូវនិងលុបបំបាត់របស់ភ្នាក់ងារត្រួតពិនិត្យ

ភ្នាក់ងារត្រួតពិនិត្យត្រូវមានឧបករណ៍សំរាប់ត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់ ដើម្បីចាត់វិធានការកែតំរូវឱ្យទាន់ពេលវេលា ។ ឧបករណ៍ទាំងនេះរួមមាន សិទ្ធិដកហូតអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ ឬសមត្ថភាពផ្តល់អនុសាសន៍



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបានឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

អំពីការដកហូតយកអាជ្ញាប័ណ្ណមកវិញ ប្រសិនបើអាចធ្វើបាន ។

## គោលការណ៍ទី ២៤ : ការត្រួតពិនិត្យប្រមូលផ្តុំ

ធាតុសំខាន់មួយនៃការត្រួតពិនិត្យធនាគារតំរូវអោយភ្នាក់ងារត្រួតពិនិត្យ ធ្វើការត្រួតពិនិត្យក្រុមធនាគារដោយឈរលើមូលដ្ឋានប្រមូលផ្តុំ ធ្វើការតាមដានឱ្យបានគ្រប់គ្រាន់ ហើយប្រសិនបើអាចធ្វើបាន ត្រូវអនុវត្តន៍បទដ្ឋានប្រុងប្រយ័ត្នចំពោះគ្រប់ប្រតិបត្តិការអាជីវកម្មរបស់ក្រុមធនាគារដែលធ្វើប្រតិបត្តិការទូទាំងពិភពលោក ។

## គោលការណ៍ទី ២៥ : ទំនាក់ទំនងរវាងភ្នាក់ងារត្រួតពិនិត្យក្នុងស្រុក និងភ្នាក់ងារអន្តរជាតិ

ការត្រួតពិនិត្យប្រមូលផ្តុំឆ្លងប្រទេស តំរូវឱ្យមានកិច្ចសហប្រតិបត្តិការនិងផ្លាស់ប្តូរព័តិមានរវាងភ្នាក់ងារត្រួតពិនិត្យក្នុងស្រុកនិងភ្នាក់ងារត្រួតពិនិត្យផ្សេងៗទៀតដែលពាក់ព័ន្ធ ជាពិសេស ភ្នាក់ងារត្រួតពិនិត្យក្នុងស្រុក។ ភ្នាក់ងារត្រួតពិនិត្យធនាគារត្រូវតែតំរូវឱ្យធនាគារបរទេសដែលធ្វើប្រតិបត្តិការក្នុងស្រុក អនុវត្តន៍តាមស្តង់ដារដែលបានដាក់ឱ្យគ្រឹះស្ថានក្នុងស្រុកអនុវត្តន៍ ។

## រូបភាពទី ២ : និទ្ទាបនិកករកិច្ចព្រមព្រៀងបាសែល ២

កិច្ចព្រមព្រៀងបាសែល ២ បានផ្តល់បទដ្ឋានអន្តរជាតិសំរាប់ការគណនាតម្រូវការដើមទុន សំរាប់ដំណើការត្រួតពិនិត្យ និងសំរាប់ជំរុញវិន័យកម្មទីផ្សារ ទៅតាមគំនូសបំព្រួញដូចខាងក្រោម :



ការពិភាក្សាអំពីកិច្ចព្រមព្រៀងស្តីពីដើមទុនដែលបានពិនិត្យកែតំរូវឡើងវិញ (Basel II) ជាដំបូងមានបំណងដាក់ឱ្យអនុវត្តជារួម ចំពោះធនាគារដែលមានប្រតិបត្តិការជាអន្តរជាតិ និងចំពោះគ្រឹះស្ថានហិរញ្ញវត្ថុដែលគ្រប់គ្រងធនាគារជាក្រុម ។ ជាបណ្តើរៗ កិច្ចព្រមព្រៀងនេះបានក្លាយជាបទដ្ឋានសំរាប់ធនាគារទាំងអស់អនុវត្ត ។ វិធីសាស្ត្រសាមញ្ញត្រូវបានបង្កើតឡើង ដើម្បីសំរួលដល់ធនាគារនិងប្រព័ន្ធហិរញ្ញវត្ថុដែលមិនមានលក្ខណៈសាំញ៉ាំ (ដែលមិនមានចំណាត់ថ្នាក់ខាងក្រៅ ឬ/និង ចំណាត់ថ្នាក់ផ្ទៃក្នុង) ។

## អ្វីដែលថ្មីពីកិច្ចព្រមព្រៀងបាសែល ១ ?

### មូលដ្ឋានគ្រឹះទី ១

- ✓ បន្ថែមលើកាតព្វកិច្ចដើមទុនអប្បរមាចំពោះហានិភ័យឥណទាននិងហានិភ័យទីផ្សារ កិច្ចព្រមព្រៀងបាសែលថ្មីតំរូវឱ្យមានកាតព្វកិច្ចដើមទុនអប្បបរមាសំរាប់ហានិភ័យប្រតិបត្តិការ ។
- ✓ ដើម្បីគណនាកាតព្វកិច្ចដើមទុនអប្បបរមាសំរាប់ប្រភេទហានិភ័យនីមួយៗ ធនាគារមានជំរើសក្នុងការប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ដូចជាវិធីសាស្ត្រចំណាត់ថ្នាក់ស្តង់ដារ ឬវិធីសាស្ត្រចំណាត់ថ្នាក់ផ្ទៃក្នុង ឬការធ្វើចំណាត់ថ្នាក់ ផ្ទៃក្នុង ។
- ✓ វិធីសាស្ត្រដែលបញ្ចូលធាតុពិតនៃហានិភ័យប្រសើរជាង ។
- ✓ ការបញ្ចូលគ្នារវាងកាតព្វកិច្ចដើមទុនតាមបញ្ញត្តិ និងដើមទុនសេដ្ឋកិច្ច ។

### មូលដ្ឋានគ្រឹះទី ២

- ✓ អាជ្ញាធរត្រួតពិនិត្យអាចមានលទ្ធភាពធ្វើការកែតំរូវកាតព្វកិច្ចដើមទុន ផ្អែកទៅតាមប្រវត្តិហានិភ័យរបស់ធនាគារនីមួយៗ ។

### មូលដ្ឋានគ្រឹះទី ៣

- ✓ តំរូវការឱ្យគ្រឹះស្ថានហិរញ្ញវត្ថុបោះផ្សាយព័ត៌មានលំអិតបន្ថែម ជាពិសេស ព័ត៌មានស្តីពីហានិភ័យនិងភាពគ្រប់គ្រាន់នៃដើមទុន ។

### រូបភាពទី ៣ : កាតព្វកិច្ចដើមទុនអប្បបរមា

$$\frac{\text{កាតព្វកិច្ចដើមទុនតំរូវដោយច្បាប់ (និយមន័យនៅដដែល)}}{\text{ហានិភ័យឥណទាន + ហានិភ័យទីផ្សារ + ហានិភ័យប្រតិបត្តិការ}} \geq ៨\%$$



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបានឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ

## ភាពពាក់ព័ន្ធនឹងកម្ពុជា

ដោយសារបាសែល ២ ជាដំបូងរៀបចំឡើងជាបទដ្ឋានសំរាប់ធនាគារធំៗនៅក្នុងប្រទេសឧស្សាហកម្មទាំង ១០ វាមានសារៈសំខាន់និងមានតំលៃដែលអាចទទួលយកបានដោយប្រទេសជាច្រើននៅលើពិភពលោក ។ យោងទៅតាមវិទ្យាស្ថានស្ថេរភាពហិរញ្ញវត្ថុ មានប្រទេសប្រមាណ ១០០ មានបំណងអនុវត្តន៏បាសែល ២ នៅក្នុងក្របខ័ណ្ឌត្រួតពិនិត្យរបស់ខ្លួន ។ ប្រទេសជិតខាងកម្ពុជាដូចជា ប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបូរី និងហ្វីលីពីន មានបំណងអនុវត្តន៏បាសែល ២ នៅដំណាច់ឆ្នាំ ២០១០ ។ ក្នុងចំណោមលក្ខខណ្ឌដំបូងសំរាប់ការអនុវត្តគោលការណ៍ថ្មីប្រកបដោយជោគជ័យដូចជាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថេរភាពនយោបាយ ការអនុវត្តបាសែល ២ មិនអាចផ្តាច់ចេញពីការអនុវត្តគោលការណ៍ស្នូលទាំង ២៥ នោះទេ ។ ការរៀបចំដំណើរការទៅតាមលំដាប់លំដោយគឺមានសារៈសំខាន់ណាស់ ។ ប្រសិនបើគ្មានក្របខ័ណ្ឌគតិយុត្តនិងបុរេលក្ខខណ្ឌផ្សេងទៀតត្រូវបានរៀបចំរួចជាស្រេចនៅក្នុងគោលការណ៍ស្នូលទាំង ២៥ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពក៏មិនអាចសំរេចបានដែរ ។

នៅក្នុងបរិបទប្រទេសកម្ពុជា យើងចាំបាច់ទទួលស្គាល់ថា ប្រព័ន្ធធនាគារស្ថិតនៅក្នុងដំណាក់កាលក្មេងខ្ចីហើយស្ថាប័នត្រួតពិនិត្យក៏ស្ថិតនៅក្មេងខ្ចីដែរ ។ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៩៩ ហើយនាយកដ្ឋានត្រួតពិនិត្យចាប់ផ្តើមដំណើរការពេញលេញនៅក្នុងឆ្នាំ ២០០១ តាមរយៈការអនុវត្តប្លង់គណនីឯកភាពសំរាប់ធនាគារទាំងអស់ ។ នៅដំណាច់ឆ្នាំ ២០០៣ ការអនុវត្តប្លង់គណនីឯកភាពត្រូវបានបញ្ចប់ ។ ការអនុវត្តប្លង់គណនីឯកភាពជាជំហានឆ្ពោះទៅរកប្រព័ន្ធរាយការណ៍ហិរញ្ញវត្ថុមួយ ប្រកបដោយតម្លាភាពនិងអាចជឿជាក់បាន ដូចនេះបានធ្វើអោយការត្រួតពិនិត្យមានប្រសិទ្ធភាព ។ យ៉ាងណាមិញ យោងទៅតាមការវាយតំលៃមិនផ្លូវការដោយមូលនិធិរូបិយវត្ថុអន្តរជាតិ មានបញ្ហាជាច្រើនបានលើកឡើងនៅក្នុងគោលការណ៍ស្នូលទាំង ២៥ ដែលមិនមានចែងនៅក្នុងច្បាប់និងបទបញ្ជាប្រុងប្រយ័ត្ន ដោយសារបញ្ហាទាំងនោះពាក់ព័ន្ធនឹងប្រព័ន្ធធនាគារនាពេលបច្ចុប្បន្ន ។ ប្រការនេះជាឧបសគ្គមួយក្នុងការអនុវត្តគោលការណ៍បាសែលប្រកបដោយជោគជ័យ ។ ឧបសគ្គផ្សេងទៀតពាក់ព័ន្ធនឹងកំរិតនៃការអភិវឌ្ឍន៏ប្រព័ន្ធធនាគារនៅក្នុងប្រទេសកម្ពុជាដូចដែលបានលើកឡើងថា ប្រព័ន្ធធនាគារនៅកម្ពុជាមានលក្ខណៈក្មេងខ្ចីនៅឡើយ ។ មូលដ្ឋានអាជីវកម្មនៅមានលក្ខណៈទន់ខ្សោយ (ជំនឿទុកចិត្តពីសាធារណជន បទប្បញ្ញត្តិ និងក្របខ័ណ្ឌគតិយុត្ត) ហើយប្រតិបត្តិការអាជីវកម្មនៅមានលក្ខណៈសមញ្ញនៅឡើយ (ការផ្គត់ផ្គង់ផលិតផល ប្រព័ន្ធព័ត៌មាន និងប្រភពធនធាន) ។ ដោយសារឧបសគ្គទាំងនេះហើយបានដាក់សំពាធដល់ធនាគារជាតិនៃកម្ពុជាក្នុងការកំណត់អនុបាតសាធនភាពសំរាប់ធនាគារខ្ពស់ជាងស្តង់ដាកំណត់នៅក្នុងបាសែល ១ ។ ដោយសារការអនុវត្តបាសែល ១ មិនទាន់បានពេញលេញនិងមិនគិតគូរពីចំនុចខ្វះខាតរបស់បាសែល ១ ជាជំហាន

ដំបូងធនាគារជាតិនៃកម្ពុជាព្យាយាមអនុវត្តគោលការណ៍ស្នូលទាំង ២៥ ឱ្យបានពេញលេញ ដែលជាមូលដ្ឋានគ្រឹះ សំរាប់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ។ ចំពោះការអនុវត្តបាសែល ២ តំរូវឱ្យមានពេលវេលាសមស្រប ។ ទីផ្សារហិរញ្ញវត្ថុមិនទាន់មានការអភិវឌ្ឍន៏នៅក្នុងប្រទេសកម្ពុជា ហើយផលិតផលហិរញ្ញវត្ថុដែលផ្តល់ដោយធនាគារមានភាពសាមញ្ញ ជាពិសេសឥណទានមានរយៈពេលខ្លីហើយជាទូទៅធានាដោយអចលនទ្រព្យ ។ ជាលទ្ធផល ហានិភ័យទាំងឡាយពាក់ព័ន្ធជាមួយហានិភ័យទីផ្សារ (ហានិភ័យជួញដូរមូលប័ត្រនិងហានិភ័យអត្រាការប្រាក់) មិនមានកើតឡើងនៅក្នុងទីផ្សារកម្ពុជានោះទេ ។ ហានិភ័យអត្រាប្តូរប្រាក់ក៏មិនមានកើតឡើងដែរ ដោយសារប្រទេសកម្ពុជាមានកំរិតដុល្លាររូបនីយកម្មខ្ពស់ហើយប្រាក់បញ្ញើជារូបិយវត្ថុក្នុងស្រុកមានត្រឹមតែ ៣% ប៉ុណ្ណោះ ។ បន្ថែមពីនេះវិធីសាស្រ្តដែលតំរូវដោយកិច្ចព្រមព្រៀងបាសែលថ្មីមិនអាចអនុវត្តបាននៅក្នុងប្រទេសកម្ពុជា ។ កង្វះខាតទិន្នន័យ ស្ថិតិ និងធនធានមនុស្សបានធ្វើអោយមានការលំបាកសំរាប់ធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តបាសែលថ្មី ។ ទោះបីជាមានឧបសគ្គទាំងនេះក៏ដោយ ធនាគារជាតិនៃកម្ពុជាបានដឹងពីតំរូវការក្នុងការដោះស្រាយបញ្ហាមួយចំនួន ដែលកើតឡើងនៅក្នុងបាសែល ២ ដែលផ្តល់នូវជំហានសំរាប់ឆ្ពោះទៅរកការអនុវត្តកិច្ចព្រមព្រៀងបាសែលថ្មីនាពេលខាងមុខ ។ បញ្ហាទាំងនោះមានដូចជា :

- នៅក្នុងការគណនាអនុបាតសាធនភាព ធនាគារជាតិនៃកម្ពុជាថ្លឹងឥណទានចំពោះស្ថាប័នអធិបតេយ្យ និងឥណទានអន្តរធនាគារ អនុលោមទៅតាមចំណាត់ថ្នាក់សមាភាគីរបស់ភ្នាក់ងារធ្វើចំណាត់ថ្នាក់អន្តរជាតិ ។
- បទបញ្ញត្តិថ្មីស្តីពីហានិភ័យឥណទានធំៗបានដាក់អោយអនុវត្តនាពេលថ្មីៗនេះ ដែលកំរិតអតិបរមានៃការផ្តល់ឥណទានផ្អែកលើចំណាត់ថ្នាក់របស់កូនបំណុលឬភាគីធានា ។
- មានកិច្ចខិតខំជាច្រើនត្រូវបានធ្វើឡើងដើម្បីរៀបចំទីផ្សារហិរញ្ញវត្ថុ ។ បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើចំណាត់ថ្នាក់ហានិភ័យប្រទេស ដោយភ្នាក់ងារធ្វើចំណាត់ថ្នាក់អន្តរជាតិ ។
- វត្តមាននៃធនាគារខ្នាតអន្តរជាតិ ដែលតំរូវឱ្យមានសូចនាករសំខាន់ៗសំរាប់ធនាគារមេ នឹងផ្តល់មូលដ្ឋានសំរាប់មន្ត្រីត្រួតពិនិត្យក្នុងការបង្កើនចំណេះដឹង ។
- ដើម្បីជំរុញវិន័យកម្មទីផ្សារ ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវបានតំរូវអោយបោះផ្សាយរបាយការណ៍សវនកម្មរបស់ស្នងការគណនីឯករាជ្យ ។ យ៉ាងណាមិញ នៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីជំរុញសុក្រិតភាពនៃព័ត៌មានដែលបង្ហាញនៅលើរបាយការណ៍ហិរញ្ញវត្ថុ ។
- ធនាគារជាតិនៃកម្ពុជា បានធ្វើការសហការយ៉ាងជិតស្និទជាមួយមន្ត្រីត្រួតពិនិត្យផ្សេងទៀតនៅក្នុងតំបន់ហើយជំរុញការធ្វើទំនាក់ទំនងតាមរយៈកិច្ចព្រមព្រៀងទ្វេរភាគីនិងជំនួបផ្សេងៗ ដូចជាការបណ្តុះបណ្តាលរៀបចំឡើងដោយ SEACEN ដែលធនាគារជាតិនៃកម្ពុជាជាសមាជិកមួយផងដែរ ។



មតិ និងយោបល់ ដែលបញ្ចេញក្នុងអត្ថបទនេះ មិនបាន ឆ្លុះបង្ហាញពីជំហររបស់ធនាគារជាតិនៃកម្ពុជាទេ